ព្រះរាជាណាចក្រកម្ពុជា

ជាតិ  សាសនា  ព្រះមហាក្សត្រ

ឆ្នាំទី២៤ លេខ៦៣ ត្រីមាសទី០៣ ឆ្នាំ២០២៤

# រាជកិច្ច

ផ្សាយចេញពី

ទីស្ដីការគណៈរដ្ឋមន្ត្រី

សារបាន

ព្រះរាជក្រម ព្រះរាជក្រឹត្យ អនុក្រឹត្យ សេចក្ដីសម្រេច បទបញ្ជា សារាចរ ប្រកាស

# ក

# មាតិកា

## I~ព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ

### ១~ព្រះរាជក្រម


២០-៨-២០២៤ -ព្រះរាជក្រម នស/រកម/០៨២៤/០០៣ ស្ដីពី ការប្រកាសឱ្យប្រើ ច្បាប់ស្ដីពីការអនុម័តយល់ព្រមលើអនុសញ្ញា ស្ដីពី ឯកភាវូបនីយកម្មនៃវិធានមួយចំនួនពាក់ព័ន្ធនឹងការដឹកជញ្ជូនអន្តរជាតិតាមផ្លូវអាកាស ៨៤៩៥


### ២~ព្រះរាជក្រឹត្យ


១៥-៧-២០២៤ -ព្រះរាជក្រឹត្យ នស/រកត/០៧២៤/៨០៤ ស្ដីពី ការតែងតាំង និងផ្ដល់ឋានៈជាជំនួយការនៃក្រសួងរ៉ែ និងថាមពល ៨រូប ៨៥៣៩

១៦-៧-២០២៤ -ព្រះរាជក្រឹត្យ នស/រកត/០៧២៤/៨០៨ ស្ដីពី ការបញ្ចប់មុខតំណែងពីសមាជិកអចិន្ត្រៃយ៍នៃក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ នៃទីស្ដីការគណៈរដ្ឋមន្ត្រី ២រូប ៨៥៤០

១៦-៧-២០២៤ -ព្រះរាជក្រឹត្យ នស/រកត/០៧២៤/៨០៩ ស្ដីពី ការតម្លើងឋានន្តរស័ក្ដិ ដល់នាយទាហាន ថ្នាក់ឧត្តមសេនីយ៍ និងថ្នាក់វរសេនីយ៍ នៃកងយោធពលខេមរភូមិន្ទ ដែលត្រូវចូលនិវត្តន៍ ចំនួន ៨រូប និងដាក់ឱ្យចូលនិវត្តន៍ ដល់នាយទាហាន នៃកងយោធពលខេមរភូមិន្ទ ផ្ទេរទៅក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ចំនួន ៨រូប ៨៥៤១

១៦-៧-២០២៤ -ព្រះរាជក្រឹត្យ នស/រកត/០៧២៤/៨១០ ស្ដីពី ការតម្លើងឋានន្តរស័ក្ដិ ជាកិច្ចបច្ឆាមរណៈចំពោះនាយទាហាន ថ្នាក់ឧត្តមសេនីយ៍ និងថ្នាក់វរសេនីយ៍ នៃកងយោធពលខេមរភូមិន្ទ ៥រូប ដែលបានទទួលមរណភាព ៨៥៤៣

១៦-៧-២០២៤ -ព្រះរាជក្រឹត្យ នស/រកត/០៧២៤/៨១១ ស្ដីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយសតាមលំដាប់ថ្នាក់ ដល់ប្រធាន អនុប្រធាន សមាជិក និងសមាជិកា នៃគណៈកម្មាធិការជាតិរៀបចំវចនានុក្រមខ្មែរ ៥រូប តាមសំណើទីស្ដីការគណៈរដ្ឋមន្ត្រី ៨៥៤៥

១៦-៧-២០២៤ -ព្រះរាជក្រឹត្យ នស/រកត/០៧២៤/៨១២ ស្ដីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយសតាមលំដាប់ថ្នាក់ ដល់សមាជិកក្រុមប្រឹក្សាខេត្តតាកែវ ១៩រូប តាមសំណើក្រសួងមហាផ្ទៃ ៨៥៤៦

១៦-៧-២០២៤ -ព្រះរាជក្រឹត្យ នស/រកត/០៧២៤/៨១៨ ស្ដីពី ការផ្ដល់គោរមងារ ឧកញ៉ា **ជឹម ឃាន** ជាអ្នកឧកញ៉ា ៨៥៤៧

១៦-៧-២០២៤ -ព្រះរាជក្រឹត្យ នស/រកត/០៧២៤/៨១៩ ស្ដីពី ការផ្ដល់គោរមងារ ឧកញ៉ា **ឡុច សារ៉េត** ជាអ្នកឧកញ៉ា ៨៥៤៨

១៦-៧-២០២៤ -ព្រះរាជក្រឹត្យ នស/រកត/០៧២៤/៨២០ ស្ដីពី ការផ្ដល់គោរមងារ លោក **ឃុន ហេង** ជាឧកញ៉ា ៨៥៤៩

១៦-៧-២០២៤ -ព្រះរាជក្រឹត្យ នស/រកត/០៧២៤/៨២១ ស្ដីពី ការផ្ដល់គោរមងារ លោកស្រី **អ៊ាង និធិវង្សនីដឺណេ** ជា ឧកញ៉ា ៨៥៥០

| | | |
|---|---|---|
| ១៦-៧-២០២៤ | -ព្រះរាជក្រឹត្យ នស/រកត/០៧២៤/៨២២ ស្ដីពី ការកែសម្រួលសមាសភាពក្រុមប្រឹក្សាគណៈស្ថាបត្យករកម្ពុជា និងអគ្គលេខាធិការដ្ឋាននៃគណៈស្ថាបត្យករកម្ពុជា | ៨៥៥១ |
| ១៧-៧-២០២៤ | -ព្រះរាជក្រឹត្យ នស/រកត/០៧២៤/៨២៣ ស្ដីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយសដល់សមាជិកក្រុមប្រឹក្សាក្រុង ស្រុក នៃរដ្ឋបាលខេត្តកំពង់ចាម ១០៥រូប តាមសំណើក្រសួងមហាផ្ទៃ | ៨៥៥៤ |
| ១៧-៧-២០២៤ | -ព្រះរាជក្រឹត្យ នស/រកត/០៧២៤/៨២៤ ស្ដីពី ការតែងតាំងឯកឧត្តមបណ្ឌិត **គី សេរីវឌ្ឍន៍** ជាទីប្រឹក្សាផ្ទាល់សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ដោយពុំទទួលប្រាក់បំណាច់មុខងារ | ៨៥៥៦ |
| ១៧-៧-២០២៤ | -ព្រះរាជក្រឹត្យ នស/រកត/០៧២៤/៨២៥ ស្ដីពី ការអនុញ្ញាតឱ្យលោកស្រី **រស់ ផូរា** ចៅក្រមសាលាឧទ្ធរណ៍បាត់ដំបង ដែលដល់អាយុចូលនិវត្តន៍ បន្តការងាររយៈពេល ១ (មួយ)ឆ្នាំ | ៨៥៥៧ |
| ១៨-៧-២០២៤ | -ព្រះរាជក្រឹត្យ នស/រកត/០៧២៤/៨២៦ ស្ដីពី ការតែងតាំងមុខតំណែងឯកឧត្តមបណ្ឌិត **រ័ត្ន ឆាវ** ជាអគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន គណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា | ៨៥៥៨ |
| ១៨-៧-២០២៤ | -ព្រះរាជក្រឹត្យ នស/រកត/០៧២៤/៨២៧ ស្ដីពី ការដាក់មន្ត្រីរាជការចំនួន ២រូប របស់ក្រសួងសុខាភិបាល ឱ្យចូលនិវត្តន៍មុនអាយុកំណត់តាមការស្នើសុំរបស់សាមីខ្លួន | ៨៥៥៩ |


## II~រាជរដ្ឋាភិបាល

### ១~អនុក្រឹត្យ


| | | |
|---|---|---|
| ១០-៧-២០២៤ | -អនុក្រឹត្យលេខ ១៥៦ អនក្រ.បក ស្ដីពី ការផ្ទេរ និងការធ្វើអនុប្បយោគ | ៨៥៦១ |
| ១១-៧-២០២៤ | -អនុក្រឹត្យលេខ ១៥៧ អនក្រ.បក ស្ដីពី ការតែងតាំងសមាសភាពគណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្មថ្នាក់ជាតិ | ៨៥៦៣ |
| ១៥-៧-២០២៤ | -អនុក្រឹត្យលេខ ១៥៨ អនក្រ.បក ស្ដីពី នីតិវិធីគ្រប់គ្រង និងការអនុវត្តថវិកាសម្រាប់យុទ្ធនាការជំរុញការចុះបញ្ជីដីធ្លីលើកដំបូងដែលមានលក្ខណៈជាប្រព័ន្ធ | ៨៥៦៦ |
| ១៥-៧-២០២៤ | -អនុក្រឹត្យលេខ ១៥៩ អនក្រ.បក ស្ដីពី ការកែសម្រួលអនុក្រឹត្យស្ដីពីការបង្កើតក្រុមហ៊ុនអាកាសចរណ៍ជាតិ | ៨៥៧០ |
| ៥-៧-២០២៤ | -អនុក្រឹត្យលេខ ៦៧៨ អនក្រ.តត ស្ដីពី ការជូនមេដាយការងារជូនបុគ្គលិកអប់រំ ៤២៣រូប | ៨៥៧២ |
| ៥-៧-២០២៤ | -អនុក្រឹត្យលេខ ៦៧៩ អនក្រ.តត ស្ដីពី ការជូនមេដាយការងារជូនបុគ្គលិកអប់រំ ៥៣៦រូប | ៨៥៨៦ |


### ២~សេចក្ដីសម្រេច


| | | |
|---|---|---|
| ១៦-៧-២០២៤ | -សេចក្ដីសម្រេចលេខ ១៣៧ សសរ ស្ដីពី ការតែងតាំងសមាសភាពបន្ថែមក្នុងក្រុមការងារពិសេសរបស់នាយករដ្ឋមន្ត្រីលើកិច្ចការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តសកម្មភាពនិងវិធានការអាទិភាពក្នុងវិស័យអប់រំ | ៨៦០៥ |
| ១៦-៧-២០២៤ | -សេចក្ដីសម្រេចលេខ ១៣៨ សសរ ស្ដីពី ការបង្កើតគណៈកម្មាធិការប្រតិបត្តិដឹកនាំការអនុវត្តផែនទីបង្ហាញផ្លូវការអភិវឌ្ឍវិស័យយានយន្ត និងអេឡិចត្រូនិកកម្ពុជា | ៨៦០៧ |

១៦-៧-២០២៤ -សេចក្តីសម្រេចលេខ ១៣៩ សសរ ស្តីពី ការតែងតាំងសមាសភាពនៃអាជ្ញាធរជាតិទប់ស្កាត់អាវុធគីមីនុយក្លេអ៊ែរ ជីវសាស្ត្រ និងវិទ្យុសកម្ម ៨៦១៩

## III~ការងារបណ្តាក្រសួង

### ទីស្តីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

២៥-៦-២០២៤ -ប្រកាសលេខ ៣៨១ សហវ.ប្រក.នធក ស្តីពី ការបង្កើតក្រុមការងារអន្តរក្រសួងដើម្បីអនុវត្តការធានារ៉ាប់រងជាកាតព្វកិច្ច ៨៦២២

២៤-៥-២០២៤ -ប្រកាសអន្តរក្រសួងលេខ ៣៣៣ សហវ.ប្រក.អថ ស្តីពី ការដាក់ឱ្យអនុវត្តអង្គភាពថវិកា ៨៦២៧

នស/រកម/០៨២៤/០០៧

# ព្រះរាជក្រម

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១១២៣/០២០ ចុះថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតរដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីការអនុម័តយល់ព្រមលើអនុសញ្ញាស្តីពីឯកភាវូបនីយកម្មនៃវិធានមួយចំនួនពាក់ព័ន្ធនឹងការដឹកជញ្ជូនអន្តរជាតិតាមផ្លូវអាកាស ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០២៤ នាសម័យប្រជុំរដ្ឋសភាលើកទី២ នីតិកាលទី៧ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០២៤ នាសម័យប្រជុំព្រឹទ្ធសភាជាវិសាមញ្ញ នីតិកាលទី៥ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ៖

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

# ច្បាប់
## ស្តីពី
## ការអនុម័តយល់ព្រមលើអនុសញ្ញាស្តីពីឯកភាវូបនីយកម្ម នៃវិធានមួយចំនួនពាក់ព័ន្ធនឹងការដឹកជញ្ជូនអន្តរជាតិតាមផ្លូវអាកាស

**មាត្រា១ ._**

អនុម័តយល់ព្រមលើអនុសញ្ញាស្តីពីឯកភាវូបនីយកម្មនៃវិធានមួយចំនួនពាក់ព័ន្ធនឹងការដឹកជញ្ជូនអន្តរជាតិតាមផ្លូវអាកាស ធ្វើនៅទីក្រុងម៉ុងរ៉េអាល់នៃប្រទេសកាណាដា នាថ្ងៃទី២៨ ខែឧសភា ឆ្នាំ១៩៩៩ ហើយដែលមានអត្ថបទទាំងស្រុងភ្ជាប់មកជាមួយនេះ។

**មាត្រា២ ._**

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាត្រូវបន្តរាល់នីតិវិធីដើម្បីអនុវត្តអនុសញ្ញានេះ។

**មាត្រា៣ ._**

ច្បាប់នេះត្រូវបានប្រកាសជាការប្រញាប់។

ថ្ងៃអង្គារ ១៣រោច ខែស្រាពណ៍ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ២០ ខែសីហា ឆ្នាំ២០២៤

នស.រកម.០៨២៤.០១៩

នរោត្តម សីហមុនី

**នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
សូមឡាយព្រះហស្តលេខា
**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
**រដ្ឋមន្ត្រីទទួលបន្ទុករដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល**

**ម៉ៅ ហាវណ្ណាល់**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**
**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**វង្សី វិស្សុត**

# អនុសញ្ញា

# ស្តីពី

# ឯកភាវូបនីយកម្មនៃវិធានមួយចំនួន

# ពាក់ព័ន្ធនឹងការដឹកជញ្ជូនអន្តរជាតិ

# តាមផ្លូវអាកាស

# អនុសញ្ញា
# ស្តីពី
# ឯកភាវូបនីយកម្មនៃវិធានមួយចំនួន
# ពាក់ព័ន្ធនឹងការដឹកជញ្ជូនអន្តរជាតិតាមផ្លូវអាកាស

បណ្តារដ្ឋភាគីនៃអនុសញ្ញានេះ៖

**ដោយទទួលស្គាល់** ការរួមចំណែកយ៉ាងសំខាន់ នៃអនុសញ្ញាស្តីពីឯកភាវូបនីយកម្មនៃវិធានមួយចំនួនពាក់ព័ន្ធនឹងការដឹកជញ្ជូនអន្តរជាតិតាមផ្លូវអាកាស ចុះហត្ថលេខានៅទីក្រុងវ៉ាសូវី កាលពីថ្ងៃទី១២ ខែតុលា ឆ្នាំ១៩២៩ ដែលតទៅហៅថា "**អនុសញ្ញាវ៉ាសូវី**" និងលិខិតូបករណ៍ពាក់ព័ន្ធ ផ្សេងៗ ដើម្បីសុខដុមនីយកម្មនៃច្បាប់អាកាសចរណ៍អន្តរជាតិ ឯកជន

**ដោយទទួលស្គាល់** តម្រូវការក្នុងការធ្វើទំនើបកម្មនិងការរួមបញ្ចូលអនុសញ្ញាវ៉ាសូវី ព្រមទាំងលិខិតូបករណ៍ពាក់ព័ន្ធផ្សេងៗ

**ដោយទទួលស្គាល់** សារៈសំខាន់នៃការធានាការពារផលប្រយោជន៍អ្នកប្រើប្រាស់ក្នុងការដឹកជញ្ជូនអន្តរជាតិតាមផ្លូវអាកាស និងតម្រូវការផ្តល់សំណងដោយសមធម៌ ផ្អែកលើគោលការណ៍បដិទាន

**ដោយបញ្ជាក់អះអាងឡើងវិញ** នូវបំណងប្រាថ្នាក្នុងការអភិវឌ្ឍតាមលំដាប់លំដោយនៃប្រតិបត្តិការដឹកជញ្ជូនអន្តរជាតិតាមផ្លូវអាកាស និងដំណើរការដោយរលូននៃអ្នកដំណើរ អីវ៉ាន់ និងទំនិញ ដោយអនុលោមតាមគោលការណ៍និងគោលបំណងនៃអនុសញ្ញាស្តីពីអាកាសចរណ៍ស៊ីវិលអន្តរជាតិ ដែលបានធ្វើនៅទីក្រុងស៊ីកាហ្គោ កាលពីថ្ងៃទី៧ ខែធ្នូ ឆ្នាំ១៩៤៤

**ដោយជឿជាក់ថា** សកម្មភាពរួមរបស់បណ្តារដ្ឋភាគីក្នុងការធ្វើសុខដុមនីយកម្ម និងចងក្រងបញ្ញត្តិមួយចំនួនគ្រប់គ្រងការដឹកជញ្ជូនអន្តរជាតិតាមផ្លូវអាកាសបន្ថែមទៀត តាមរយៈអនុសញ្ញាថ្មីមួយ គឺជាមធ្យោបាយ សមស្របបំផុត ដើម្បីសម្រេចឱ្យបាននូវផលប្រយោជន៍ដែលមានតុល្យភាពប្រកបដោយសមធម៌

បានព្រមព្រៀង ដូចតទៅ៖

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

### មាត្រា១ .- វិសាលភាពនៃការអនុវត្ត

១- អនុសញ្ញានេះអនុវត្តចំពោះការដឹកជញ្ជូនបុគ្គល អីវ៉ាន់ ឬទំនិញ តាមផ្លូវអាកាសអន្តរជាតិទាំងអស់ដែលប្រតិបត្តិដោយអាកាសយាន ដើម្បីទទួលបាននូវផលប្រយោជន៍។ អនុសញ្ញានេះក៏អនុវត្តដោយស្មើភាពផងដែរចំពោះការដឹកជញ្ជូនតាមអាកាសយានដោយមិនយកកម្រៃ ដែលប្រតិបត្តិដោយសហគ្រាសដឹកជញ្ជូនតាមផ្លូវអាកាសមួយ។

២- តាមគោលបំណងនៃអនុសញ្ញានេះ ការប្រើប្រាស់ពាក្យ "ការដឹកជញ្ជូនអន្តរជាតិ" សំដៅដល់ការដឹកជញ្ជូន ដែលយោងតាមការព្រមព្រៀងរបស់គូភាគី មានចំណុចចេញដំណើរនិងចំណុចគោលដៅ ទោះមានឬមិនមានការឈប់សំចត ឬការផ្ទេរទំនិញក៏ដោយ ស្ថិតនៅក្នុងទឹកដីនៃរដ្ឋភាគីពីរ ឬនៅក្នុងទឹកដីនៃរដ្ឋភាគីតែមួយ ប្រសិនបើកន្លែងឈប់សំចតត្រូវបានគ្រោងទុកនៅក្នុងទឹកដីនៃរដ្ឋភាគីមួយទៀត ទោះជារដ្ឋភាគីនោះពុំមែនជារដ្ឋភាគីក៏ដោយ។ ការដឹកជញ្ជូនរវាងពីរចំណុច នៅក្នុងទឹកដីនៃរដ្ឋភាគីតែមួយ ដោយពុំមានការឈប់សំចតនៅក្នុងទឹកដីនៃរដ្ឋភាគីមួយផ្សេងទៀត គឺពុំមែនជាការដឹកជញ្ជូនអន្តរជាតិទេ តាមគោលបំណងនៃអនុសញ្ញានេះ។

៣- តាមគោលបំណងនៃអនុសញ្ញានេះ ការដឹកជញ្ជូនដែលប្រតិបត្តិដោយក្រុមហ៊ុនដឹកជញ្ជូនច្រើនបន្តបន្ទាប់គ្នា ត្រូវចាត់ទុកថា ជាការដឹកជញ្ជូនតែមួយ ប្រសិនបើគូភាគីសន្មតថា ជាប្រតិបត្តិការតែមួយ ទោះជាមានការព្រមព្រៀងគ្នាក្រោមទម្រង់ជាកិច្ចសន្យាទោលឬកិច្ចសន្យាច្រើនក៏ដោយ ហើយការដឹកជញ្ជូននេះមិនបាត់បង់ចរិតលក្ខណៈអន្តរជាតិ ដោយគ្រាន់តែកិច្ចសន្យាមួយឬកិច្ចសន្យាច្រើន ត្រូវបានអនុវត្តទាំងស្រុងនៅក្នុងទឹកដីនៃរដ្ឋភាគីដូចគ្នាមួយ។

៤- អនុសញ្ញានេះក៏អនុវត្តផងដែរ ចំពោះការដឹកជញ្ជូនដែលមានចែងក្នុងជំពូកទី៥ អាស្រ័យតាមខ្លឹមសារដែលមានចែងក្នុងជំពូកនោះ។

## មាត្រា២ .- ការដឹកជញ្ជូនដែលធ្វើឡើងដោយរដ្ឋភាគីនិងការដឹកជញ្ជូនបញ្ញើប្រៃសណីយ៍

១- អនុសញ្ញានេះអនុវត្តចំពោះការដឹកជញ្ជូន ដែលធ្វើឡើងដោយរដ្ឋភាគីឬដោយអង្គភាពសាធារណៈ ស្របច្បាប់ក្នុងលក្ខខណ្ឌដែលមានចែងក្នុងមាត្រា១។

២- ក្នុងការដឹកជញ្ជូនបញ្ញើប្រៃសណីយ៍ ក្រុមហ៊ុនដឹកជញ្ជូនទទួលខុសត្រូវតែចំពោះរដ្ឋបាលប្រៃសណីយ៍ពាក់ព័ន្ធប៉ុណ្ណោះ ដោយអនុលោមតាមវិធាននានា ដែលអនុវត្តលើទំនាក់ទំនងរវាងក្រុមហ៊ុនដឹកជញ្ជូន និងរដ្ឋបាលប្រៃសណីយ៍។

៣- លើកលែងតែមានចែងក្នុងចំណុចទី២នៃមាត្រានេះ បទប្បញ្ញត្តិនៃអនុសញ្ញានេះមិនត្រូវអនុវត្តចំពោះការដឹកជញ្ជូនបញ្ញើប្រៃសណីយ៍ឡើយ។

# ជំពូកទី២
# ឯកសារនិងភារកិច្ចរបស់គូភាគីពាក់ព័ន្ធការដឹកជញ្ជូនអ្នកដំណើរអីវ៉ាន់និងទំនិញ
## មាត្រា៣ .- អ្នកដំណើរនិងអីវ៉ាន់

១- ក្នុងការដឹកជញ្ជូនអ្នកដំណើរ ឯកសារដឹកជញ្ជូនឯកត្តជនឬសមូហភាពនឹងត្រូវផ្តល់ជូនដែលក្នុងនោះ ត្រូវមាន៖

(ក) ការបញ្ជាក់ចំណុចចេញដំណើរនិងចំណុចគោលដៅ។

(ខ) ការបញ្ជាក់ចំណុចឈប់សំចតយ៉ាងហោចណាស់មួយកន្លែង ប្រសិនបើចំណុចចេញដំណើរនិងចំណុចគោលដៅស្ថិតនៅក្នុងទឹកដីនៃរដ្ឋភាគីតែមួយ ហើយមានចំណុចឈប់សំចតដែលបានព្រមព្រៀងមួយឬច្រើននៅក្នុងទឹកដីនៃរដ្ឋភាគីមួយផ្សេងទៀត។

២- ការប្រើមធ្យោបាយផ្សេងទៀត ដែលរក្សាព័ត៌មានដូចបានបញ្ជាក់ក្នុងចំណុចទី១ អាចជំនួសដោយការផ្តល់ឯកសារ ដូចមានចែងក្នុងចំណុចនោះ។ ប្រសិនបើមធ្យោបាយផ្សេងទៀតត្រូវបានប្រើប្រាស់ ក្រុមហ៊ុនដឹកជញ្ជូនត្រូវផ្តល់ជូនអ្នកធ្វើដំណើរនូវឯកសារជាលាយលក្ខណ៍អក្សរមួយ ដែលរក្សាព័ត៌មានដូចមានចែងក្នុងនោះ។

៣- ក្រុមហ៊ុនដឹកជញ្ជូនត្រូវផ្តល់សលាកបត្រសម្គាល់អីវ៉ាន់ជូនអ្នកដំណើរ សម្រាប់កញ្ចប់អីវ៉ាន់នីមួយៗដែលបានផ្ញើ។

៤- នៅពេលដែលអនុសញ្ញានេះត្រូវអនុវត្ត អ្នកដំណើរត្រូវបានជូនដំណឹងជាលាយលក្ខណ៍អក្សរស្តីពីការគ្រប់គ្រង និងអាចដាក់កម្រិតការទទួលខុសត្រូវរបស់ក្រុមហ៊ុនដឹកជញ្ជូនទាក់ទងនឹងមរណភាពឬការរងរបួស ក៏ដូចជាការបំផ្លាញ ឬការបាត់បង់ ឬការខូចខាតអីវ៉ាន់ និងការយឺតយ៉ាវ។

៥- ការមិនអនុលោមតាមបទប្បញ្ញត្តិនៃចំណុចខាងលើ មិនប៉ះពាល់ដល់អត្ថិភាពឬសុពលភាពនៃកិច្ចសន្យាដឹកជញ្ជូន ដែលមិនស្ថិតនៅក្រោមវិធាននៃអនុសញ្ញានេះ រួមទាំងវិធានទាំងឡាយពាក់ព័ន្ធទៅនឹងការដាក់កម្រិតការទទួលខុសត្រូវឡើយ។

## មាត្រា៤ .- ទំនិញ

១- ក្នុងករណីដឹកជញ្ជូនទំនិញ អញ្ញត្តិបណ្ណដឹកជញ្ជូនតាមផ្លូវអាកាសត្រូវផ្តល់ជូន។

២- ការប្រើប្រាស់មធ្យោបាយដទៃទៀតដែលរក្សាទុកកំណត់ត្រានៃការដឹកជញ្ជូន គឺអាចជំនួសការផ្តល់អញ្ញត្តិបណ្ណដឹកជញ្ជូន។ ប្រសិនបើមធ្យោបាយនេះត្រូវបានប្រើប្រាស់ ក្រុមហ៊ុនដឹកជញ្ជូនត្រូវផ្តល់ជូនអ្នកផ្ញើនូវបង្កាន់ដៃទំនិញ ដែលមានអត្តសញ្ញាណទំនិញនិងព័ត៌មានក្នុងកំណត់ត្រាដែលបានរក្សាទុកតាមមធ្យោបាយទាំងនេះ ប្រសិនបើមានការស្នើសុំពីអ្នកផ្ញើ។

## មាត្រា៥ .- មាតិកានៃអញ្ញត្តិបណ្ណដឹកជញ្ជូនទំនិញតាមផ្លូវអាកាសឬបង្កាន់ដៃទំនិញ

អញ្ញត្តិបណ្ណដឹកជញ្ជូនទំនិញតាមផ្លូវអាកាសឬបង្កាន់ដៃទំនិញ ត្រូវមានៈ

(ក) ការបញ្ជាក់ចំណុចចេញដំណើរនិងចំណុចគោលដៅ។

(ខ) ការបញ្ជាក់ចំណុចឈប់សំចតយ៉ាងហោចណាស់មួយកន្លែង ប្រសិនបើចំណុចចេញដំណើរនិងចំណុចគោលដៅស្ថិតនៅក្នុងទឹកដីនៃរដ្ឋភាគីតែមួយ ហើយមានចំណុចឈប់សំចតដែលបានព្រមព្រៀងមួយឬច្រើននៅក្នុងទឹកដីនៃរដ្ឋភាគីមួយផ្សេងទៀត។

(គ) ការបញ្ជាក់ទម្ងន់នៃបញ្ញើ។

## មាត្រា៦ .- ឯកសារពាក់ព័ន្ធនៅនឹងលក្ខណៈទំនិញ

អ្នកផ្ញើអាចតម្រូវឱ្យផ្តល់ឯកសារបញ្ជាក់លក្ខណៈនៃទំនិញ ដើម្បីបំពេញបែបបទគយ នគរបាល និងអាជ្ញាធរសាធារណៈប្រហាក់ប្រហែល ក្នុងករណីចាំបាច់។ បទប្បញ្ញត្តិនេះមិនបង្កើតបន្ទុក កាតព្វកិច្ចឬការទទួលខុសត្រូវដល់ក្រុមហ៊ុនដឹកជញ្ជូនទេ ក្នុងការបំពេញបែបបទទាំងនេះ។

## មាត្រា៧ .- ការបរិយាយអញ្ញត្តិបណ្ណដឹកជញ្ជូនតាមផ្លូវអាកាស

១- អញ្ញត្តិបណ្ណដឹកជញ្ជូនតាមផ្លូវអាកាស ត្រូវរៀបចំដោយអ្នកផ្ញើ ជាបីសន្លឹកច្បាប់ដើម។

២- សន្លឹកទីមួយត្រូវបានបោះសម្គាល់ "សម្រាប់ក្រុមហ៊ុនដឹកជញ្ជូន" ហើយចុះហត្ថលេខាដោយអ្នកផ្ញើ។ សន្លឹកទីពីរត្រូវបានបោះសម្គាល់ "សម្រាប់អ្នកទទួល" ហើយចុះហត្ថលេខាដោយអ្នកផ្ញើនិងក្រុមហ៊ុនដឹកជញ្ជូន។ សន្លឹកទីបីចុះហត្ថលេខាដោយក្រុមហ៊ុនដឹកជញ្ជូន ដែលត្រូវប្រគល់ជូនអ្នកផ្ញើ បន្ទាប់ពីបានទទួលទំនិញ។

៣- ហត្ថលេខារបស់ក្រុមហ៊ុនដឹកជញ្ជូននិងហត្ថលេខារបស់អ្នកផ្ញើ អាចត្រូវបានធ្វើឡើង ឬបោះត្រា។

៤- ប្រសិនបើមានសំណើរបស់អ្នកផ្ញើ ក្រុមហ៊ុនដឹកជញ្ជូនរៀបចំអញ្ញត្តិបណ្ណដឹកជញ្ជូនតាមផ្លូវអាកាស ដោយសន្មតថាបានរៀបចំឡើងក្នុងនាមអ្នកផ្ញើ លើកលែងតែមានភស្តុតាងបញ្ជាក់ផ្ទុយពីនេះ។

## មាត្រា៨ .- ឯកសារទំនិញច្រើនកញ្ចប់

នៅពេលមានទំនិញលើសពីមួយកញ្ចប់៖

(ក) ក្រុមហ៊ុនដឹកជញ្ជូនទំនិញមានសិទ្ធិតម្រូវឱ្យអ្នកផ្ញើ រៀបចំអញ្ញត្តិបណ្ណដឹកជញ្ជូនតាមផ្លូវអាកាសដាច់ដោយឡែកពីគ្នា។

(ខ) អ្នកផ្ញើមានសិទ្ធិតម្រូវឱ្យក្រុមហ៊ុនដឹកជញ្ជូន ផ្តល់បង្កាន់ដៃទំនិញដាច់ដោយឡែកពីគ្នា នៅពេលដែលមធ្យោបាយផ្សេងទៀត ដូចមានចែងក្នុងចំណុចទី២នៃមាត្រា៤ខាងលើ ត្រូវបានប្រើប្រាស់។

## មាត្រា៩ .- ការមិនអនុលោមតាមលក្ខខណ្ឌតម្រូវឯកសារ

ការមិនអនុលោមតាមបទប្បញ្ញត្តិនៃមាត្រា៤ដល់មាត្រា៨ មិនប៉ះពាល់ដល់អត្ថិភាពឬសុពលភាពកិច្ចសន្យាដឹកជញ្ជូន ដែលមិនស្ថិតនៅក្រោមវិធាននៃអនុសញ្ញានេះ រួមទាំងវិធានទាំងឡាយដែលពាក់ព័ន្ធទៅនឹងការដាក់កម្រិតការទទួលខុសត្រូវឡើយ។

## មាត្រា១០ .- ការទទួលខុសត្រូវចំពោះលក្ខណៈពិសេសនៃឯកសារ

១- អ្នកផ្ញើត្រូវទទួលខុសត្រូវចំពោះភាពត្រឹមត្រូវនូវលក្ខណៈពិសេសនិងព័ត៌មានទំនិញ ដែលបានកត់ត្រាចូលអញ្ញត្តិបណ្ណដឹកជញ្ជូនតាមផ្លូវអាកាស ដោយអ្នកផ្ញើឬអ្នកតំណាង ឬក៏ផ្តល់ដោយអ្នកផ្ញើឬអ្នកតំណាងទៅឱ្យក្រុមហ៊ុនដឹកជញ្ជូន ដើម្បីកត់ត្រាចូលក្នុងបង្កាន់ដៃទំនិញ ឬក្នុងកំណត់ត្រា ដែលត្រូវរក្សាទុកដោយមធ្យោបាយផ្សេងទៀត ដូចមានចែងនៅក្នុងចំណុចទី២នៃមាត្រា៤។ បទប្បញ្ញត្តិខាងលើនេះក៏អនុវត្តដែរ នៅពេលបុគ្គលតំណាងអ្នកផ្ញើជាភ្នាក់ងាររបស់ក្រុមហ៊ុនដឹកជញ្ជូនផងដែរ។

២- អ្នកផ្ញើត្រូវទូទាត់សំណងជូនក្រុមហ៊ុនដឹកជញ្ជូន នូវរាល់ការខូចខាតទាំងឡាយណាដែលបានកើតឡើងចំពោះក្រុមហ៊ុនដឹកជញ្ជូន ឬបុគ្គលស្ថិតក្រោមបន្ទុកក្រុមហ៊ុនដឹកជញ្ជូន ដោយសារតែភាពមិនប្រក្រតី ភាពមិនត្រឹមត្រូវ ឬភាពមិនពេញលេញនៃលក្ខណៈពិសេសនិងព័ត៌មានទំនិញផ្ដល់ដោយអ្នកផ្ញើឬតំណាង។

៣- យោងតាមបទប្បញ្ញត្តិនៃចំណុចទី១និងចំណុចទី២នៃមាត្រានេះ ក្រុមហ៊ុនដឹកជញ្ជូនត្រូវទូទាត់សំណងជូនអ្នកផ្ញើនូវរាល់ការខូចខាតទាំងឡាយណា ដែលបានកើតឡើងចំពោះអ្នកផ្ញើឬបុគ្គលស្ថិតក្រោមបន្ទុកអ្នកផ្ញើ ដោយសារតែភាពមិនប្រក្រតី ភាពមិនត្រឹមត្រូវ ឬភាពមិនពេញលេញនៃលក្ខណៈពិសេសនិងព័ត៌មានទំនិញ ដែលក្រុមហ៊ុនដឹកជញ្ជូន ឬតំណាង កត់ត្រាចូលក្នុងបង្កាន់ដៃទំនិញ ឬកំណត់ត្រារក្សាទុកតាមមធ្យោបាយផ្សេងទៀត ដូចមានចែងក្នុងចំណុចទី២នៃមាត្រា៤។

## មាត្រា១១ .- តម្លៃជាភស្តុតាងនៃឯកសារ

១- អញ្ញត្តិបណ្ណដឹកជញ្ជូនតាមផ្លូវអាកាសឬបង្កាន់ដៃទំនិញ គឺជាភស្តុតាងដំបូងលើការព្រមព្រៀងនៃកិច្ចសន្យាលើការទទួលយកទំនិញនិងលើលក្ខខណ្ឌដឹកជញ្ជូន ដែលមានចែងនៅក្នុងនោះ។

២- ការប្រកាសព័ត៌មានក្នុងអញ្ញត្តិបណ្ណដឹកជញ្ជូនតាមផ្លូវអាកាសឬបង្កាន់ដៃទំនិញពាក់ព័ន្ធនឹងទម្ងន់ វិមាត្រនិងការវេចខ្ចប់នៃទំនិញ ក៏ដូចជាចំនួននៃកញ្ចប់ទំនិញ គឺជាភស្តុតាងដំបូងនៃការប្រកាសភាពពិតប្រាកដ។ ការប្រកាសព័ត៌មានពាក់ព័ន្ធនឹងបរិមាណ ទំហំ និងលក្ខខណ្ឌនៃទំនិញ មិនអាចចាត់ទុកជាភស្តុតាង តវ៉ាជាមួយក្រុមហ៊ុនដឹកជញ្ជូនបានទេ ដរាបណាព័ត៌មានទាំងនេះចែងក្នុងអញ្ញត្តិបណ្ណដឹកជញ្ជូនតាមផ្លូវអាកាសឬបង្កាន់ដៃទំនិញ ត្រូវបានបញ្ជាក់ដោយក្រុមហ៊ុនដឹកជញ្ជូន ក្រោមវត្តមានអ្នកផ្ញើឬយោងតាមលក្ខខណ្ឌជាក់ស្ដែងនៃទំនិញ។

## មាត្រា១២ .- សិទ្ធិរៀបចំចាត់ចែងទំនិញ

១- យោងតាមការទទួលខុសត្រូវរបស់ខ្លួនក្នុងការបំពេញកាតព្វកិច្ច ស្ថិតក្រោមកិច្ចសន្យាដឹកជញ្ជូន អ្នកផ្ញើមានសិទ្ធិរៀបចំចាត់ចែងទំនិញ ដូចជាយកទំនិញចេញពីអាកាសយានដ្ឋានចេញដំណើរ ឬអាកាសយានដ្ឋានគោលដៅ ឬក្នុងកំឡុងពេលឈប់សំចត ឬក៏ស្នើសុំឱ្យបញ្ជូនទំនិញទៅកាន់ចំណុចគោលដៅ ឬក៏ក្នុងពេលដឹកជញ្ជូនឱ្យទៅបុគ្គលណាម្នាក់មិនមែនជាអ្នកទទួលដែលបានកំណត់ពីដំបូង ឬក៏ស្នើសុំឱ្យយកទំនិញមកអាកាសយានដ្ឋានចេញដំណើរវិញ។ អ្នកផ្ញើមិនត្រូវអនុវត្តសិទ្ធិរៀបចំចាត់ចែងទំនិញ ដែលបង្កឱ្យប៉ះពាល់ដល់ក្រុមហ៊ុនដឹកជញ្ជូនឬអ្នកផ្ញើដទៃផ្សេងទៀត ហើយត្រូវទូទាត់សងចំណាយផ្សេងៗដែលកើតឡើងដោយការអនុវត្តសិទ្ធិនេះ។

២- ប្រសិនបើមិនអាចអនុវត្តតាមការណែនាំរបស់អ្នកផ្ញើ ក្រុមហ៊ុនដឹកជញ្ជូនត្រូវជូនដំណឹងភ្លាមទៅអ្នកផ្ញើ។

៣- ប្រសិនបើក្រុមហ៊ុនដឹកជញ្ជូនអនុវត្តតាមការណែនាំរបស់អ្នកផ្ញើលើការចាត់ចែងទំនិញ ដោយពុំតម្រូវឱ្យមានការផ្តល់សន្លឹកអញ្ញត្តិបណ្ណដឹកជញ្ជូនតាមផ្លូវអាកាសឬបង្កាន់ដៃទំនិញទៅអ្នកផ្ញើ ក្រុមហ៊ុនដឹកជញ្ជូនត្រូវទទួលខុសត្រូវលើការខូចខាតដែលអាចបង្កឡើងតាមរយៈព្រឹត្តិការណ៍ខាងលើ ដល់បុគ្គលដែលកំពុងកាន់កាប់សន្លឹកអញ្ញត្តិបណ្ណដឹកជញ្ជូនតាមផ្លូវអាកាស ឬបង្កាន់ដៃទំនិញដោយស្របច្បាប់ ហើយការទទួលខុសត្រូវនេះ នឹងមិនប៉ះពាល់ដល់សិទ្ធិរបស់ក្រុមហ៊ុនដឹកជញ្ជូនក្នុងការទាមទារយកសំណងពីអ្នកផ្ញើឡើយ។

៤- សិទ្ធិខាងលើរបស់អ្នកផ្ញើត្រូវអស់សុពលភាព នៅពេលដែលសិទ្ធិអ្នកទទួលចាប់ផ្តើមមានសុពលភាព ដោយអនុលោមតាមមាត្រា១៣។ ទោះជាយ៉ាងនេះក្តី ប្រសិនបើអ្នកទទួលបដិសេធមិនទទួលយកទំនិញ ឬមិនអាចទាក់ទងបានសិទ្ធិរៀបចំចាត់ចែងទំនិញរបស់អ្នកផ្ញើមានសុពលភាពឡើងវិញ។

## មាត្រា១៣ .- ការប្រគល់ទំនិញ

១- លើកលែងតែក្នុងករណីដែលអ្នកផ្ញើអនុវត្តសិទ្ធិរបស់ខ្លួនស្របតាមមាត្រា១២ អ្នកទទួលមានសិទ្ធិតម្រូវឱ្យក្រុមហ៊ុនដឹកជញ្ជូនប្រគល់ទំនិញមកខ្លួន នៅពេលទំនិញមកដល់ចំណុចគោលដៅ ដោយទូទាត់ថ្លៃចំណាយ និងដោយអនុវត្តតាមលក្ខខណ្ឌនៃការដឹកជញ្ជូន។

២- ក្រុមហ៊ុនដឹកជញ្ជូនមានកាតព្វកិច្ចជូនដំណឹងដល់អ្នកទទួល ឱ្យបានឆាប់នៅពេលទំនិញមកដល់ លើកលែងតែមានការព្រមព្រៀងផ្សេងពីនេះ។

៣- ប្រសិនបើក្រុមហ៊ុនដឹកជញ្ជូនទទួលស្គាល់ថា បាត់ទំនិញឬទំនិញមិនទាន់មកដល់ បន្ទាប់ពីរយៈពេលប្រាំពីរ (៧)ថ្ងៃនៃកាលបរិច្ឆេទដែលត្រូវមកដល់ អ្នកទទួលមានសិទ្ធិតវ៉ាជាមួយក្រុមហ៊ុនដឹកជញ្ជូន ដោយអនុវត្តសិទ្ធិដែលមានចែងក្នុងកិច្ចសន្យាដឹកជញ្ជូន។

## មាត្រា១៤ .- ការអនុវត្តសិទ្ធិរបស់អ្នកផ្ញើនិងអ្នកទទួល

អ្នកផ្ញើនិងអ្នកទទួលអាចអនុវត្តសិទ្ធិរៀងៗខ្លួន ដែលមានចែងក្នុងមាត្រា១២និងមាត្រា១៣ ដោយប្រើឈ្មោះរបស់ខ្លួន ទោះជាដើម្បីជាផលប្រយោជន៍ផ្ទាល់ខ្លួនឬផលប្រយោជន៍អ្នកដទៃ ក្នុងលក្ខខណ្ឌដែលអនុវត្តកាតព្វកិច្ចដូចមានចែងក្នុងកិច្ចសន្យាដឹកជញ្ជូន។

## មាត្រា១៥ .- ទំនាក់ទំនងរវាងអ្នកផ្ញើនិងអ្នកទទួលឬទំនាក់ទំនងទៅវិញទៅមកជាមួយតតិយជន

១- មាត្រា១២ មាត្រា១៣ និងមាត្រា១៤ មិនប៉ះពាល់នោះទេ ដល់ទំនាក់ទំនងរវាងអ្នកផ្ញើនិងអ្នកទទួល ឬទំនាក់ទំនងទៅវិញទៅមកជាមួយតតិយជន ដែលសិទ្ធិរបស់តតិយជនបានទទួលពីអ្នកផ្ញើឬពីអ្នកទទួល។

២- បទប្បញ្ញត្តិនៃមាត្រា១២ មាត្រា១៣ និងមាត្រា១៤ អាចប្រែប្រួលបានតាមរយៈបទប្បញ្ញត្តិបញ្ជាក់នៅក្នុងអញ្ញត្តិបណ្ណដឹកជញ្ជូនតាមផ្លូវអាកាសឬបង្កាន់ដៃទំនិញតែប៉ុណ្ណោះ។

## មាត្រា១៦ .- បែបបទគយ នគរបាល ឬអាជ្ញាធរសាធារណៈផ្សេងៗ

១- អ្នកផ្ញើត្រូវផ្តល់ព័ត៌មាននិងឯកសារដែលចាំបាច់ដើម្បីបំពេញបែបបទគយ នគរបាល និងអាជ្ញាធរសាធារណៈផ្សេងៗ មុនពេលទំនិញអាចផ្តល់ជូនទៅឱ្យអ្នកទទួល។ អ្នកផ្ញើត្រូវទទួលខុសត្រូវចំពោះក្រុមហ៊ុនដឹកជញ្ជូនសម្រាប់ការខូចខាត ដែលបានកើតឡើងដោយសារតែអវត្តភាព ឬភាពមិនគ្រប់គ្រាន់ ឬភាពមិនប្រក្រតីនៃព័ត៌មានឬឯកសារទាំងនោះ លើកលែងតែការខូចខាតបណ្តាលមកពីកំហុសរបស់ក្រុមហ៊ុនដឹកជញ្ជូនឬបុគ្គលិក ឬភ្នាក់ងាររបស់ក្រុមហ៊ុន។

២- ក្រុមហ៊ុនដឹកជញ្ជូនពុំស្ថិតក្រោមកាតព្វកិច្ចដើម្បីធ្វើការផ្ទៀងផ្ទាត់ភាពត្រឹមត្រូវ ឬភាពគ្រប់គ្រាន់នៃព័ត៌មាន ឬឯកសារទាំងនោះទេ។

## ជំពូកទី៣
## ការទទួលខុសត្រូវរបស់ក្រុមហ៊ុនដឹកជញ្ជូននិងវិសាលភាពសំណងលើការខូចខាត

### មាត្រា១៧ .- មរណភាពនិងការរងរបួសរបស់អ្នកដំណើរ ការខូចខាតអីវ៉ាន់

១- ក្រុមហ៊ុនដឹកជញ្ជូនត្រូវទទួលខុសត្រូវលើការខូចខាត ក្នុងករណីមរណភាពឬរងរបួសផ្នែករាងកាយរបស់អ្នកដំណើរ ក្នុងលក្ខខណ្ឌតែមួយដែលឧបទ្ទវហេតុបង្កឱ្យមានមរណភាព ឬការរងរបួស បានកើតឡើងនៅក្នុងអាកាសយាន ឬក្នុងពេលដំណើរការឡើងឬចុះពីអាកាសយាន។

២- ក្រុមហ៊ុនដឹកជញ្ជូនត្រូវទទួលខុសត្រូវលើការខូចខាត ក្នុងករណីមានការបំផ្លិចបំផ្លាញ ឬបាត់បង់ ឬខូចខាតចំពោះអីវ៉ាន់ផ្ញើ ក្នុងលក្ខខណ្ឌតែមួយដែលព្រឹត្តិការណ៍បង្កឱ្យមានការបំផ្លិចបំផ្លាញ បាត់បង់ ឬខូចខាត បានកើតឡើងនៅក្នុងអាកាសយាន ឬក្នុងរង្វង់រយៈពេលអីវ៉ាន់ផ្ញើនៅក្នុងបន្ទុករបស់ក្រុមហ៊ុនដឹកជញ្ជូន។ ទោះជាយ៉ាងណាក្តី ក្រុមហ៊ុនដឹកជញ្ជូនមិនទទួលខុសត្រូវ ប្រសិនបើនិងក្នុងករណីដែលការខូចខាតបណ្តាលមកពីលក្ខណៈដើម គុណភាព ឬវិការៈនៃអីវ៉ាន់។ ចំពោះអីវ៉ាន់យកតាមខ្លួន រួមទាំងរបស់របរផ្ទាល់ខ្លួន ក្រុមហ៊ុនដឹកជញ្ជូនត្រូវទទួលខុសត្រូវ ប្រសិនបើការខូចខាតកើតឡើងមកពីកំហុសរបស់ក្រុមហ៊ុនឬបុគ្គលិក ឬភ្នាក់ងាររបស់ក្រុមហ៊ុន។

៣- ប្រសិនបើក្រុមហ៊ុនដឹកជញ្ជូនទទួលស្គាល់ការបាត់អីវ៉ាន់ផ្ញើ ឬប្រសិនបើអីវ៉ាន់ផ្ញើពុំបានមកដល់ក្នុងរយៈពេលផុតកំណត់២១(ម្ភៃមួយ)ថ្ងៃ បន្ទាប់ពីកាលបរិច្ឆេទដែលត្រូវមកដល់ អ្នកដំណើរអាចប្រើប្រាស់សិទ្ធិតវ៉ាជាមួយក្រុមហ៊ុនដឹកជញ្ជូនដែលសិទ្ធិនេះមានចែងក្នុងកិច្ចសន្យាដឹកជញ្ជូន។

៤- នៅក្នុងអនុសញ្ញានេះ ពាក្យ "អីវ៉ាន់" សំដៅដល់ទាំងអីវ៉ាន់ផ្ញើនិងអីវ៉ាន់យកតាមខ្លួន លើកលែងតែមានបញ្ជាក់ផ្ទុយពីនេះ។

### មាត្រា១៨ .- ការខូចខាតទំនិញ

១- ក្រុមហ៊ុនដឹកជញ្ជូនត្រូវទទួលខុសត្រូវលើការខូចខាត ក្នុងករណីមានការបំផ្លិចបំផ្លាញ ឬបាត់បង់ ឬខូចខាតចំពោះទំនិញ ក្នុងលក្ខខណ្ឌមួយដែលព្រឹត្តិការណ៍នោះបង្កឱ្យមានការខូចខាត បានកើតឡើងក្នុងកំឡុងពេលនៃការដឹកជញ្ជូនតាមផ្លូវអាកាស។

២- ក៏ប៉ុន្តែ ក្រុមហ៊ុនដឹកជញ្ជូនមិនទទួលខុសត្រូវឡើយ ប្រសិនបើនិងក្នុងករណីដែលក្រុមហ៊ុនមានភស្តុតាងបញ្ជាក់ថា ការបំផ្លិចបំផ្លាញ ឬការបាត់បង់ ឬការខូចខាតចំពោះទំនិញ បានកើតឡើងពីមូលហេតុមួយឬច្រើនដូចខាងក្រោម៖

(ក) លក្ខណៈដើម គុណភាព ឬវិការៈនៃទំនិញ។

(ខ) ការវេចខ្ចប់ទំនិញមិនត្រឹមត្រូវ ដោយបុគ្គលម្នាក់ដែលមិនមែនជាក្រុមហ៊ុនឬបុគ្គលិក ឬភ្នាក់ងាររបស់ក្រុមហ៊ុន។

(គ) ព្រឹត្តិការណ៍សង្គ្រាម ឬជម្លោះប្រដាប់អាវុធ។

(ឃ) ទង្វើរបស់អាជ្ញាធរសាធារណៈដែលបានធ្វើឡើង ពាក់ព័ន្ធនឹងការចូល ការចេញ ឬការឆ្លងកាត់ទំនិញ។

៣- ការដឹកជញ្ជូនតាមផ្លូវអាកាស តាមន័យចំណុចទី១នៃមាត្រានេះ គឺរួមទាំងរយៈពេលដែលទំនិញស្ថិតនៅក្នុងបន្ទុករបស់ក្រុមហ៊ុនដឹកជញ្ជូន។

៤- រយៈពេលនៃការដឹកជញ្ជូនតាមផ្លូវអាកាស គឺមិនរាប់បញ្ចូលរយៈពេលនៃការដឹកជញ្ជូនតាមផ្លូវគោក សមុទ្រ ឬផ្លូវទឹកនៃដែនដី ដែលដឹកជញ្ជូននៅក្រៅអាកាសយានដ្ឋាន។ ទោះជាយ៉ាងនេះក្តី ប្រសិនបើការដឹកជញ្ជូននេះអនុវត្តតាមកិច្ចសន្យាដឹកជញ្ជូនតាមផ្លូវអាកាស ក្នុងគោលបំណងផ្ទុក ឬប្រគល់ ឬផ្ទេរទំនិញ ការខូចខាតណាមួយត្រូវបានសន្មតថា គឺជាការកើតឡើងក្នុងរយៈពេលនៃការដឹកជញ្ជូនតាមផ្លូវអាកាស លើកលែងតែមានភស្តុតាងផ្ទុយពីនេះ។ ប្រសិនបើក្រុមហ៊ុនដឹកជញ្ជូនជំនួសមធ្យោបាយដឹកជញ្ជូនផ្សេងទៀត សម្រាប់ការដឹកជញ្ជូនទាំងស្រុង ឬមួយផ្នែក ដែលគូភាគីបានព្រមព្រៀងជាការដឹកជញ្ជូនតាមផ្លូវអាកាស ដោយពុំមានការយល់ព្រមពីអ្នកផ្ញើទេ នោះការដឹកជញ្ជូនតាមមធ្យោបាយផ្សេងទៀតនោះ ត្រូវចាត់ទុកថា នៅក្នុងរយៈពេលនៃការដឹកជញ្ជូនតាមផ្លូវអាកាស។

## មាត្រា១៩ .- ការយឺតយ៉ាវ

ក្រុមហ៊ុនដឹកជញ្ជូន ត្រូវទទួលខុសត្រូវចំពោះការខូចខាតដែលបណ្តាលមកពីការយឺតយ៉ាវក្នុងការដឹកជញ្ជូនអ្នកដំណើរ អីវ៉ាន់ ឬទំនិញតាមផ្លូវអាកាស។ ទោះជាយ៉ាងនេះក្តី ក្រុមហ៊ុនដឹកជញ្ជូនមិនទទួលខុសត្រូវចំពោះការខូចខាតដែលបណ្តាលមកពីការយឺតយ៉ាវ ប្រសិនបើក្រុមហ៊ុនមានភស្តុតាងបញ្ជាក់ថា ក្រុមហ៊ុន បុគ្គលិកនិងភ្នាក់ងាររបស់ខ្លួន បានចាត់រាល់វិធានការសមហេតុផលដែលបានតម្រូវ ដើម្បីបញ្ចៀសការខូចខាត ឬបញ្ជាក់ថា ក្រុមហ៊ុន ឬបុគ្គលិកនិងភ្នាក់ងាររបស់ក្រុមហ៊ុនពុំមានលទ្ធភាពចាត់វិធានការទាំងនោះបាន។

## មាត្រា២០ .- ការលើកលែង

ប្រសិនបើក្រុមហ៊ុនដឹកជញ្ជូនមានភស្តុតាងបញ្ជាក់ថា ការខូចខាតបណ្តាលមកពីឬមានចំណែកមកពីការធ្វេសប្រហែស ឬការប្រព្រឹត្តខុស ឬការមិនបានបំពេញកាតព្វកិច្ចរបស់អ្នកទាមទារសំណង ឬបុគ្គលដែលទទួលសិទ្ធិ ក្រុមហ៊ុនដឹកជញ្ជូនត្រូវបានរួចបន្ទុកទាំងស្រុងឬនៅផ្នែកណាមួយពីការទទួលខុសត្រូវរបស់ខ្លួនចំពោះអ្នកទាមទារសំណង ក្នុងលក្ខខណ្ឌ ដែលការខូចខាតបណ្តាលមកពីឬមានចំណែកមកពីការធ្វេសប្រហែស ឬការប្រព្រឹត្តខុស ឬការមិនបានបំពេញកាតព្វកិច្ចទាំងនេះ។ ក្នុងករណីមានមរណភាពឬរងរបួសដល់អ្នកដំណើរ នៅពេលសំណងត្រូវបានទាមទារដោយបុគ្គលម្នាក់ដែលមិនមែន ជាអ្នកដំណើរ ក្រុមហ៊ុនដឹកជញ្ជូនត្រូវបានរួចផុតទាំងស្រុងឬផ្នែកណា

មួយពីការទទួលខុសត្រូវរបស់ខ្លួន នៅពេលដែលក្រុមហ៊ុនមានភស្តុតាងបញ្ជាក់ថា ការខូចខាតនោះបណ្តាលមកពី ឬមានចំណែកមកពីការធ្វេសប្រហែស ឬ ការប្រព្រឹត្តខុស ឬការខកខានរបស់អ្នកដំណើរនោះ។ មាត្រានេះអនុវត្ត ចំពោះបទប្បញ្ញត្តិទាំងអស់ស្តីពីការទទួលខុសត្រូវសំណងនៅក្នុងអនុសញ្ញានេះ រួមទាំងចំណុចទី១នៃមាត្រា២១។

## មាត្រា២១ ._ សំណងក្នុងករណីមរណភាពឬការរងរបួសដល់អ្នកដំណើរ

១- ចំពោះការខូចខាតដែលកើតឡើងក្រោមចំណុចទី១នៃមាត្រា១៧ ដែលមិនលើសពី១០០ ០០០SDR (អេសដេអេ) សម្រាប់អ្នកដំណើរម្នាក់ ក្រុមហ៊ុនដឹកជញ្ជូនមិនអាចបដិសេធ ឬដាក់កម្រិតលើការទទួលខុសត្រូវ របស់ខ្លួនឡើយ។

២- ក្រុមហ៊ុនដឹកជញ្ជូនមិនទទួលខុសត្រូវលើការខូចខាតដែលកើតឡើងក្រោមចំណុចទី១នៃមាត្រា១៧ ក្នុងលក្ខខណ្ឌដែលការខូចខាតមានកម្រិតលើសពី១០០ ០០០SDR(អេសដេអេ) សម្រាប់អ្នកដំណើរម្នាក់ ប្រសិនបើក្រុមហ៊ុន ដឹកជញ្ជូនមានភស្តុតាងបញ្ជាក់ថា៖

(ក) ការខូចខាតនេះមិនបណ្តាលមកពីការធ្វេសប្រហែស ឬការប្រព្រឹត្តខុសផ្សេងៗ ឬការមិនបានបំពេញ កាតព្វកិច្ចរបស់ក្រុមហ៊ុនដឹកជញ្ជូនឬបុគ្គលិកឬភ្នាក់ងាររបស់ក្រុមហ៊ុន ឬ

(ខ) ការខូចខាតនេះបណ្តាលមកពីការធ្វេសប្រហែស ឬការប្រព្រឹត្តខុសផ្សេងៗ ឬការមិនបានបំពេញ កាតព្វកិច្ចរបស់តតិយជនទាំងស្រុង។

## មាត្រា២២ ._ កម្រិតការទទួលខុសត្រូវពាក់ព័ន្ធនឹងការយឺតយ៉ាវ អីវ៉ាន់ និងទំនិញ

១- ក្នុងករណីមានការខូចខាតដែលបណ្តាលមកពីការយឺតយ៉ាវ ដូចមានចែងក្នុងមាត្រា១៩ ក្នុងការដឹកជញ្ជូន អ្នកដំណើរ ការទទួលខុសត្រូវរបស់ក្រុមហ៊ុនដឹកជញ្ជូនសម្រាប់អ្នកដំណើរម្នាក់ គឺត្រូវបានកំណត់ត្រឹម៤ ១៥០SDR (អេសដេអេ)។

២- ចំពោះការដឹកជញ្ជូនអីវ៉ាន់ ក្នុងករណីមានការបំផ្លិចបំផ្លាញ បាត់បង់ ខូចខាត និងការយឺតយ៉ាវ ការទទួល ខុសត្រូវរបស់ក្រុមហ៊ុនដឹកជញ្ជូន គឺត្រូវបានកំណត់ត្រឹម១ ០០០SDR(អេសដេអេ) សម្រាប់អ្នកដំណើរម្នាក់ លើកលែងតែនៅពេលប្រគល់អីវ៉ាន់ផ្ញើជូនក្រុមហ៊ុនដឹកជញ្ជូន អ្នកផ្ញើបានធ្វើការប្រកាសពិសេសអំពីតម្លៃអីវ៉ាន់ នៅទីកន្លែងប្រគល់អីវ៉ាន់ និងបានបង់ប្រាក់បន្ថែមក្នុងករណីចាំបាច់។ ក្នុងករណីនេះ ក្រុមហ៊ុនដឹកជញ្ជូនត្រូវ ទទួលខុសត្រូវបង់ចំនួនទឹកប្រាក់ដែលមិនលើសពីចំនួនទឹកប្រាក់ដែលបានប្រកាសទេ លើកលែងតែក្រុមហ៊ុនដឹក ជញ្ជូនមានភស្តុតាងបញ្ជាក់ថាចំនួនទឹកប្រាក់នោះថ្លៃជាងតម្លៃអីវ៉ាន់ជាក់ស្តែងរបស់អ្នកផ្ញើ ដែលបានប្រកាសនៅ កន្លែងប្រគល់អីវ៉ាន់។

៣- ចំពោះការដឹកជញ្ជូនទំនិញ ក្នុងករណីមានការបំផ្លិចបំផ្លាញ បាត់បង់ ខូចខាត និងការយឺតយ៉ាវ ការទទួល ខុសត្រូវរបស់ក្រុមហ៊ុនដឹកជញ្ជូន គឺត្រូវបានកំណត់ត្រឹម១៧SDR(អេសដេអេ) ក្នុងមួយគីឡូក្រាម លើកលែងតែ នៅពេលប្រគល់ បញ្ញើទៅក្រុមហ៊ុនដឹកជញ្ជូន អ្នកផ្ញើបានធ្វើការប្រកាសពិសេសអំពីតម្លៃទំនិញ និងបានបង់ប្រាក់ បន្ថែមក្នុងករណីចាំបាច់។ ក្នុងករណីនេះ ក្រុមហ៊ុនដឹកជញ្ជូនត្រូវទទួលខុសត្រូវបង់ចំនួនទឹកប្រាក់ដែលមិនលើស ពីចំនួនទឹកប្រាក់ដែលបានប្រកាសទេ លើកលែងតែក្រុមហ៊ុនដឹកជញ្ជូនមានភស្តុតាងបញ្ជាក់ថា ចំនួនទឹកប្រាក់ នោះថ្លៃជាងតម្លៃទំនិញជាក់ស្តែងរបស់អ្នកផ្ញើ ដែលបានប្រកាសនៅកន្លែងប្រគល់ទំនិញ។

៤- ក្នុងករណីនៃការបំផ្លិចបំផ្លាញ បាត់បង់ ខូចខាត ឬយឺតយ៉ាវលើផ្នែកខ្លះនៃទំនិញ ឬវត្ថុនៅក្នុងទំនិញ ទម្ងន់ដែលត្រូវយកធ្វើជាមូលដ្ឋានដើម្បីកំណត់កម្រិតនៃការទទួលខុសត្រូវរបស់ក្រុមហ៊ុនដឹកជញ្ជូន ត្រូវតែជាទម្ងន់សរុបនៃកញ្ចប់ទំនិញពាក់ព័ន្ធមួយឬច្រើន។ ទោះជាយ៉ាងណាក្ដី នៅពេលដែលការបំផ្លិចបំផ្លាញ បាត់បង់ ខូចខាត ឬការយឺតយ៉ាវលើផ្នែកខ្លះនៃទំនិញ ឬវត្ថុនៅក្នុងទំនិញប៉ះពាល់ដល់តម្លៃកញ្ចប់ទំនិញផ្សេងទៀតដែលមានចុះក្នុងអញ្ញត្តិបណ្ណដឹកជញ្ជូនតាមផ្លូវអាកាស ឬបង្កាន់ដៃតែមួយ ឬចុះក្នុងកំណត់ត្រាដែលរក្សាទុកដោយមធ្យោបាយដទៃទៀត ដូចមានចែងក្នុងចំណុចទី២នៃមាត្រា៤ ប្រសិនបើអញ្ញត្តិបណ្ណដឹកជញ្ជូនតាមផ្លូវអាកាសនិងបង្កាន់ដៃទំនិញមិនត្រូវបានចេញឱ្យ ទម្ងន់សរុបនៃកញ្ចប់ទំនិញនេះឬកញ្ចប់ទាំងនេះ ត្រូវយកមកធ្វើជាមូលដ្ឋានដើម្បីកំណត់កម្រិតការទទួលខុសត្រូវ។

៥- បទប្បញ្ញត្តិខាងលើនៃចំណុចទី១និងទី២នៃមាត្រានេះ មិនអនុវត្ត ប្រសិនបើមានភស្តុតាងបញ្ជាក់ថាការខូចខាតបណ្តាលមកពីការប្រព្រឹត្តឬការមិនបានបំពេញកាតព្វកិច្ចរបស់ក្រុមហ៊ុនដឹកជញ្ជូន បុគ្គលិកឬភ្នាក់ងារក្រុមហ៊ុន ដែលធ្វើ ឡើងក្នុងចេតនាបង្កការខូចខាត ឬដោយខ្វះការយកចិត្តទុកដាក់ និងដោយដឹងថា ការខូចខាតអាចកើតមានឡើង ហើយក្នុងលក្ខខណ្ឌដែលការប្រព្រឹត្តឬការមិនបានបំពេញកាតព្វកិច្ចរបស់បុគ្គលិកឬភ្នាក់ងារត្រូវបានបញ្ជាក់ថា បានកើតឡើងក្នុងវិសាលភាពនៃការបំពេញការងាររបស់ពួកគេ។

៦- កម្រិតទទួលខុសត្រូវដែលមានចែងក្នុងមាត្រា២១និងក្នុងមាត្រានេះ មិនរារាំងតុលាការ លើការផ្តល់សំណងបន្ថែមទាំងស្រុងឬផ្នែកណាមួយ ដោយផ្អែកតាមច្បាប់របស់ខ្លួន នូវប្រាក់ប្រដាប់ក្តីនិងចំណាយផ្សេងៗទៀតនៃការដោះស្រាយវិវាទរបស់ដើមបណ្តឹង រួមទាំងការប្រាក់។ បទប្បញ្ញត្តិខាងលើមិនអនុវត្តទេ ប្រសិនបើចំនួនទឹកប្រាក់នៃការខូចខាតដែលផ្តល់ជូន ដោយមិនរាប់បញ្ចូលប្រាក់ប្រដាប់ក្តីនិងចំណាយផ្សេងៗទៀតនៃដំណើរការដោះស្រាយវិវាទ មិនលើសពីចំនួនទឹកប្រាក់សរុបដែលក្រុមហ៊ុនដឹកជញ្ជូនបានផ្តល់ជាលាយលក្ខណ៍អក្សរជូនដើមបណ្តឹងក្នុងរង្វង់រយៈពេល៦(ប្រាំមួយ)ខែ ចាប់ពីកាលបរិច្ឆេទនៃព្រឹត្តិការណ៍បង្កឱ្យមានការខូចខាតឬមុនពេលចាប់ផ្តើមដំណើរការរឿងក្តី ប្រសិនបើសកម្មភាពនោះកើតមានក្រោយ។

## មាត្រា២៣ .- ការប្តូរឯកតារូបិយបណ្ណ

១- ចំនួនទឹកប្រាក់ដែលបានលើកឡើង ធៀបជាមួយ"Special Drawing Right" ក្នុងអនុសញ្ញានេះ សំដៅដល់ "Special Drawing Right" ដូចបានកំណត់ដោយមូលនិធិរូបិយវត្ថុអន្តរជាតិ។ ក្នុងករណីនៃការដោះស្រាយតាមផ្លូវតុលាការ ការប្តូរចំនួនទឹកប្រាក់សរុបទៅជារូបិយបណ្ណជាតិ ត្រូវតែធ្វើឡើងដោយអនុលោមតាមតម្លៃនៃរូបិយបណ្ណជាតិទាំងនេះ ដោយធៀបជាមួយ"Special Drawing Right" នៅកាលបរិច្ឆេទនៃសេចក្តីសម្រេច។ តម្លៃនៃរូបិយបណ្ណជាតិមួយ ធៀបជាមួយ"Special Drawing Right" របស់រដ្ឋភាគីមួយជាសមាជិកនៃមូលនិធិរូបិយវត្ថុអន្តរជាតិត្រូវបានគណនា ស្របតាមវិធីសាស្ត្រនៃការវាយតម្លៃ ដែលអនុវត្តដោយមូលនិធិរូបិយវត្ថុអន្តរជាតិ សម្រាប់ប្រតិបត្តិការនិងអន្តរការណ៍ របស់ខ្លួនដោយគិតចាប់ពីកាលបរិច្ឆេទនៃសេចក្តីសម្រេច។ តម្លៃនៃរូបិយបណ្ណជាតិមួយ ធៀបជាមួយ "Special Drawing Right" របស់រដ្ឋភាគីមួយ ដែលមិនមែនជាសមាជិកមូលនិធិរូបិយវត្ថុអន្តរជាតិ ត្រូវបានគណនាតាមរបៀបដែលកំណត់ដោយរដ្ឋភាគីនោះ។

២- ទោះបីជាយ៉ាងនេះក្តី រដ្ឋភាគីទាំងឡាយដែលមិនមែនជាសមាជិកនៃមូលនិធិរូបិយវត្ថុអន្តរជាតិ និងច្បាប់របស់ខ្លួនមិនអនុញ្ញាតឱ្យអនុវត្តតាមចំណុចទី១នៃមាត្រានេះ នៅពេលផ្តល់សច្ចាប័ន ឬការចូលជាសមាជិក ឬពេលណាមួយបន្ទាប់ពីនោះ អាចប្រកាសថា កម្រិតនៃការទទួលខុសត្រូវរបស់ក្រុមហ៊ុនដឹកជញ្ជូន ដូចមានចែងក្នុងមាត្រា២១ គឺត្រូវបានកំណត់ជាចំនួនសរុប១ ៥០០ ០០០ឯកតារូបិយបណ្ណ សម្រាប់អ្នកដំណើរម្នាក់ លើការដោះស្រាយតាមផ្លូវតុលាការនៅក្នុងទឹកដីរបស់ខ្លួន ជាចំនួនសរុប៦២ ៥០០ឯកតារូបិយបណ្ណសម្រាប់អ្នកដំណើរម្នាក់ ដោយយោងតាមចំណុចទី១នៃមាត្រា២២ ជាចំនួនសរុប១៥ ០០០ឯកតារូបិយបណ្ណសម្រាប់អ្នកដំណើរម្នាក់ដោយយោងតាមចំណុចទី២នៃមាត្រា២២ និងជាចំនួនសរុប២៥០ឯកតារូបិយបណ្ណក្នុងមួយគីឡូក្រាម ដោយយោងតាមចំណុចទី៣នៃមាត្រា២២។ ឯកតារូបិយបណ្ណនេះ ស្មើនឹងហុកសិបប្រាំកន្លះមិល្លីក្រាម នៃមាសសុទ្ធខ្នាតប្រាំបួនរយភាគពាន់។ ចំនួនសរុបទាំងនេះ អាចប្តូរទៅជារូបិយបណ្ណជាតិ ដោយគិតជាលេខបង្គត់។ ការប្តូរនៃចំនួនសរុបទាំងនេះ ឱ្យទៅជារូបិយបណ្ណជាតិ ត្រូវធ្វើឡើងស្របតាមច្បាប់នៃរដ្ឋភាគីនោះ។

៣- ការគណនាដូចបានបញ្ជាក់ក្នុងវាក្យខណ្ឌចុងក្រោយនៃចំណុចទី១របស់មាត្រានេះ និងវិធីសាស្ត្រនៃការប្តូរប្រាក់ដូចបានបញ្ជាក់ក្នុងចំណុចទី២នៃមាត្រានេះ ត្រូវប្រព្រឹត្តទៅតាមរបៀបបង្ហាញជារូបិយបណ្ណជាតិនៃរដ្ឋភាគី ដែលមានតម្លៃពិតប្រាកដដូចគ្នានឹងចំនួនទឹកប្រាក់មានចែងក្នុងមាត្រា២១និងមាត្រា២២ តាមលទ្ធភាពអាចធ្វើទៅបាន ហើយជាលទ្ធផលដែលកើតចេញមកពីការអនុវត្តវាក្យខណ្ឌទាំងបីដំបូងនៃចំណុចទី១ នៃមាត្រានេះ។ បណ្តារដ្ឋភាគីត្រូវធ្វើទំនាក់ទំនងជាមួយអង្គភាពតម្កល់អនុសញ្ញាដើម្បីតម្កល់នូវរបៀបនៃការគណនា ស្របតាមចំណុចទី១ នៃមាត្រានេះឬលទ្ធផលនៃការប្តូរប្រាក់ ដូចក្នុងចំណុចទី២នៃមាត្រានេះ តាមករណីនៅពេលដែលតម្កល់លិខិតូបករណ៍សច្ចាប័ន ទទួលយក ឯកភាព ឬចូលជាសមាជិកនៃអនុសញ្ញានេះ និងនៅពេលណាដែលមានការផ្លាស់ប្តូរវិធីសាស្ត្រគណនា ឬលទ្ធផលនៃការប្តូរប្រាក់។

## មាត្រា២៤ .- ការពិនិត្យឡើងវិញនូវកម្រិតទទួលខុសត្រូវ

១- ដោយមិនប៉ះពាល់ដល់បទប្បញ្ញត្តិមាត្រា២៥នៃអនុសញ្ញានេះ និងយោងចំណុចទី២ខាងក្រោម កម្រិតនៃការទទួលខុសត្រូវ ដូចបានបញ្ជាក់ក្នុងមាត្រា២១ មាត្រា២២ និងមាត្រា២៣ ត្រូវធ្វើការពិនិត្យឡើងវិញ ដោយអង្គភាពតម្កល់អនុសញ្ញា រៀងរាល់៥(ប្រាំ)ឆ្នាំម្តង។ ការពិនិត្យឡើងវិញលើកទី១ ត្រូវប្រព្រឹត្តទៅនៅចុងឆ្នាំទី៥ ដោយគិតចាប់ពីថ្ងៃចូលជាធរមាននៃអនុសញ្ញានេះ ឬប្រសិនបើអនុសញ្ញានេះមិនទាន់ចូលជាធរមានក្នុងរង្វង់រយៈពេល៥(ប្រាំ) ឆ្នាំ គិតចាប់តាំងពីថ្ងៃដំបូងបើកឱ្យចុះហត្ថលេខា គឺនៅក្នុងរង្វង់ឆ្នាំទី១នៃការចូលជាធរមាន ដោយយោងទៅលើកត្តាអតិផរណា ដែលជាប់ពាក់ព័ន្ធនឹងអត្រាបង្គរនៃអតិផរណា ចាប់តាំងពីការពិនិត្យឡើងវិញពីមុន ឬប្រសិនបើជាករណីនៃការពិនិត្យឡើងវិញលើកទី១ ចាប់តាំងពីថ្ងៃចូលជាធរមាននៃអនុសញ្ញា។ ការវាស់វែងអត្រា អតិផរណាដើម្បីប្រើប្រាស់ក្នុងការកំណត់កត្តាអតិផរណា ត្រូវថ្លឹងថ្លែងតាមមធ្យមភាគអត្រាប្រចាំឆ្នាំនៃការកើនឡើង ឬថយចុះសន្ទស្សន៍ថ្លៃអ្នកប្រើប្រាស់របស់រដ្ឋភាគី ដែលមានរូបិយបណ្ណរបស់ខ្លួន រួមមាន Special Drawing Right ដូចបានបញ្ជាក់ក្នុងចំណុចទី១នៃមាត្រា២៣។

២- ប្រសិនបើការពិនិត្យឡើងវិញ ដូចមានចែងក្នុងចំណុចខាងលើ សម្រេចថា កត្តាអតិផរណាលើស១០% (ដប់)ភាគរយ អង្គភាពតម្កល់អនុសញ្ញាត្រូវជូនដំណឹងទៅរដ្ឋភាគី អំពីការកែសម្រួលលើកម្រិតការទទួលខុសត្រូវ។ រាល់ការកែសម្រួល ត្រូវចូលជាធរមានក្នុងរយៈពេល៦(ប្រាំមួយ)ខែ បន្ទាប់ពីការជូនដំណឹងទៅរដ្ឋភាគី។ ប្រសិនបើក្នុងកំលុងពេល៣(បី)ខែ បន្ទាប់ពីការជូនដំណឹងទៅរដ្ឋភាគី សំឡេងភាគច្រើននៃរដ្ឋភាគីពុំឯកភាព នោះការកែសម្រួលនឹងមិនអាចចូលជាធរមាន ហើយអង្គភាពតម្កល់អនុសញ្ញាត្រូវលើកបញ្ហានេះនៅក្នុងកិច្ចប្រជុំមួយរបស់រដ្ឋភាគី។ អង្គភាពតម្កល់អនុសញ្ញាត្រូវជូនដំណឹងភ្លាមៗ ទៅរដ្ឋភាគីស្តីពីការចូលជាធរមាននៃរាល់ការកែសម្រួល។

៣- ទោះជាមានចំណុចទី១នៃមាត្រានេះក៏ដោយ នីតិវិធីដែលមានចែងក្នុងចំណុចទី២នៃមាត្រានេះ ត្រូវបានអនុវត្តគ្រប់ពេលវេលា លុះត្រាតែមួយភាគបីនៃរដ្ឋភាគី បង្ហាញពីគោលជំហរគាំទ្រ ក្រោមលក្ខខណ្ឌថា កត្តា អតិផរណា ដូចមានចែងក្នុងចំណុចទី១លើសពី៣០%(សាមសិប)ភាគរយ គិតចាប់តាំងពីការកែសម្រួលលើកមុន ឬចាប់តាំងពីថ្ងៃចូលជាធរមាននៃអនុសញ្ញានេះ ប្រសិនបើពុំមានការកែសម្រួលលើកមុន។ ការត្រួតពិនិត្យឡើងវិញ ជាបន្តបន្ទាប់ដោយប្រើប្រាស់នីតិវិធី ដូចមានចែងក្នុងចំណុចទី១នៃមាត្រានេះ ត្រូវប្រព្រឹត្តទៅក្នុងចន្លោះរយៈពេល៥(ប្រាំ)ឆ្នាំ ចាប់ផ្តើមនៅចុងឆ្នាំទី៥ បន្ទាប់ពីកាលបរិច្ឆេទនៃការត្រួតពិនិត្យឡើងវិញក្រោមចំណុចនេះ។

## មាត្រា២៥ .- ការកំណត់អំពីកម្រិតទទួលខុសត្រូវ

ក្រុមហ៊ុនដឹកជញ្ជូនមួយអាចកំណត់ថា កិច្ចសន្យាដឹកជញ្ជូនអាចមានកម្រិតទទួលខុសត្រូវខ្ពស់ជាងការកម្រិតទទួលខុសត្រូវដែលមានចែងក្នុងអនុសញ្ញានេះ ឬមិនកម្រិតការទទួលខុសត្រូវណាមួយក៏បាន។

## មាត្រា២៦ .- មោឃភាពនៃបទប្បញ្ញត្តិកិច្ចសន្យា

បទប្បញ្ញត្តិទាំងឡាយ មានបំណងបន្ធូរបន្ថយការទទួលខុសត្រូវរបស់ក្រុមហ៊ុនដឹកជញ្ជូន ឬកំណត់កម្រិតទទួលខុសត្រូវទាបជាងអ្វីដែលបានកំណត់ក្នុងអនុសញ្ញានេះ ត្រូវទុកជាមោឃៈ ក៏ប៉ុន្តែមោឃភាពនៃបទប្បញ្ញត្តិណាមួយ មិនជាប់ពាក់ព័ន្ធនឹងមោឃភាពនៃកិច្ចសន្យាទាំងមូល ដែលនៅតែស្ថិតនៅក្រោមបទប្បញ្ញត្តិនៃអនុសញ្ញានេះ។

## មាត្រា២៧ .- សេរីភាពនៃការធ្វើកិច្ចសន្យា

ពុំមានបទប្បញ្ញត្តិនៃអនុសញ្ញានេះ ត្រូវហាមឃាត់ក្រុមហ៊ុនដឹកជញ្ជូនមិនឱ្យធ្វើកិច្ចសន្យាដឹកជញ្ជូន បោះបង់ការការពារខ្លួនដែលមានស្រាប់នៅក្រោមអនុសញ្ញានេះ ឬមិនឱ្យដាក់លក្ខខណ្ឌនានាដែលមិនផ្ទុយនឹងបទប្បញ្ញត្តិនៃអនុសញ្ញានេះ។

## មាត្រា២៨ .- បុរេប្រទាន

ក្នុងករណីមានគ្រោះថ្នាក់អាកាសយាន បណ្តាលឱ្យមរណភាពឬរងរបួសដល់អ្នកដំណើរ ក្រុមហ៊ុនដឹកជញ្ជូនត្រូវធ្វើបុរេប្រទានដោយពុំមានភាពយឺតយ៉ាវជូនចំពោះរូបវន្តបុគ្គលមួយឬច្រើន ដែលមានសិទ្ធិក្នុងការទាមទារសំណង ដើម្បីឆ្លើយតបតម្រូវការសេដ្ឋកិច្ចបន្ទាន់នៃបុគ្គលទាំងនោះ ប្រសិនបើច្បាប់ជាតិតម្រូវ។ បុរេប្រទានទាំងនេះមិនចាត់ទុកជាការទទួលស្គាល់នៃការទទួលខុសត្រូវ និងអាចកាត់កងជាមួយចំនួនទឹកប្រាក់ដែលក្រុមហ៊ុនដឹកជញ្ជូនត្រូវទូទាត់ជាបន្តបន្ទាប់លើការខូចខាត។

## មាត្រា២៩ .- មូលដ្ឋាននៃការទាមទារសំណង

ក្នុងការដឹកជញ្ជូនអ្នកដំណើរ អីវ៉ាន់ និងទំនិញ រាល់ការប្តឹងតវ៉ាទាមទារសំណងចំពោះការខូចខាត យោងតាមអនុសញ្ញានេះ ឬដោយយោងតាមកិច្ចសន្យា ឬដោយអំពើអនីត្យានុកូល ឬដោយមូលហេតុដទៃទៀត អាចធ្វើបានតែក្នុងលក្ខខណ្ឌនិងកម្រិតទទួលខុសត្រូវ ដែលមានចែងក្នុងអនុសញ្ញានេះ ដោយមិនប៉ះពាល់ដល់ការកំណត់បុគ្គលដែលមានសិទ្ធិប្តឹងនិងសិទ្ធិពាក់ព័ន្ធរបស់បុគ្គលទាំងនោះឡើយ។ ក្នុងករណីនៃការប្តឹងប្រភេទនេះ សំណងជាទណ្ឌកម្មជាការព្រមាន ឬសំណងមិនមែនជាការប៉ះប៉ូវផ្សេងទៀត មិនអាចទាមទារមកវិញបានឡើយ។

## មាត្រា៣០ .- បុគ្គលិក ភ្នាក់ងារ ទឹកប្រាក់សរុបនៃសំណង

១- ប្រសិនបើមានបណ្តឹងចំពោះបុគ្គលិកឬភ្នាក់ងារក្រុមហ៊ុនដឹកជញ្ជូន ដោយសារមានការខូចខាតកើតឡើងដូចមានចែងក្នុងអនុសញ្ញា បុគ្គលិកឬភ្នាក់ងារនេះត្រូវមានសិទ្ធិប្រើប្រាស់លក្ខខណ្ឌនិងកម្រិតទទួលខុសត្រូវ ដែលក្រុមហ៊ុនដឹកជញ្ជូនខ្លួនឯងមានសិទ្ធិអនុវត្តក្រោមអនុសញ្ញានេះ ប្រសិនបើបុគ្គលទាំងនោះមានភស្តុតាងបង្ហាញថាបុគ្គលទាំងនោះបានបំពេញភារកិច្ចនៅក្នុងវង្វង់វិសាលភាពនៃការងាររបស់ខ្លួន។

២- ក្នុងករណីនេះ ចំនួនទឹកប្រាក់សរុបដែលអាចត្រូវទាមទារបានមកវិញពីក្រុមហ៊ុនដឹកជញ្ជូន បុគ្គលិកនិងភ្នាក់ងាររបស់ក្រុមហ៊ុន មិនត្រូវលើសពីកម្រិតដូចបានកំណត់ឡើយ។

៣- ប៉ុន្តែចំពោះការដឹកជញ្ជូនទំនិញ បទប្បញ្ញត្តិនៃចំណុចទី១និងចំណុចទី២នៃមាត្រានេះ មិនត្រូវអនុវត្តប្រសិនបើ មានភស្តុតាងបង្ហាញថា ការខូចខាតបណ្តាលមកពីទង្វើ ឬពីការមិនបានបំពេញកាតព្វកិច្ចរបស់បុគ្គលិកឬភ្នាក់ងារ ដែលបានប្រព្រឹត្ត ក្នុងចេតនាបង្កឱ្យមានការខូចខាត ឬដោយធ្វេសប្រហែស និងទាំងបានដឹងថា ការខូចខាតអាចនឹងកើតមានឡើង។

## មាត្រា៣១ .- ការជូនដំណឹងអំពីការប្តឹងតវ៉ាឱ្យទាន់ពេល

១- ការទទួលបានអីវ៉ាន់ផ្ញើឬទំនិញដោយបុគ្គលដែលជាអ្នកមានសិទ្ធិទទួល ដោយពុំមានការប្តឹងតវ៉ា គឺជាភស្តុតាងដំបូង ដែលបង្ហាញថា អីវ៉ាន់ឬទំនិញនេះត្រូវបានប្រគល់ជូននៅក្នុងស្ថានភាពល្អ ដោយអនុលោមតាមឯកសារ ដឹកជញ្ជូន ឬតាមកំណត់ត្រាដែលត្រូវបានរក្សាទុកដោយមធ្យោបាយផ្សេងទៀតដូចមានចែងក្នុងចំណុចទី២នៃមាត្រា៣និងចំណុចទី២នៃមាត្រា៤។

២- ក្នុងករណីមានការខូចខាត បុគ្គលដែលមានសិទ្ធិទទួលអីវ៉ាន់ឬទំនិញផ្ញើ ត្រូវប្តឹងតវ៉ាទៅក្រុមហ៊ុនដឹកជញ្ជូនភ្លាមៗ បន្ទាប់ពីរកឃើញការខូចខាត និងយ៉ាងយូរបំផុតក្នុងរង្វង់រយៈពេល៧(ប្រាំពីរ)ថ្ងៃ បន្ទាប់ពីថ្ងៃទទួល ចំពោះករណីអីវ៉ាន់ផ្ញើ និងក្នុងរង្វង់រយៈពេល១៤(ដប់បួន)ថ្ងៃ បន្ទាប់ពីថ្ងៃទទួល ចំពោះករណីទំនិញ។ ក្នុងករណីមានភាពយឺតយ៉ាវ ការប្តឹងតវ៉ាត្រូវធ្វើឡើងយ៉ាងយូរបំផុតក្នុងរង្វង់រយៈពេល២១(ម្ភៃមួយ)ថ្ងៃ ចាប់ពីថ្ងៃដែលអីវ៉ាន់ឬទំនិញនេះត្រូវបានបញ្ជូនដាក់ឱ្យស្ថិតនៅក្នុងការចាត់ចែងរបស់បុគ្គលដែលមានសិទ្ធិទទួល។

៣- រាល់ការប្តឹងតវ៉ាត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ និងប្រគល់ឱ្យឬបញ្ជូនចេញនៅក្នុងរង្វង់រយៈពេល ដូចមានចែងខាងលើ។

៤- ប្រសិនបើពុំមានការប្តឹងតវ៉ាណាមួយត្រូវបានធ្វើឡើង នៅក្នុងរង្វង់រយៈពេល ដូចមានចែងខាងលើ រាល់ការប្តឹងតវ៉ាទៅក្រុមហ៊ុនដឹកជញ្ជូនមិនអាចធ្វើបានឡើយ លើកលែងតែក្នុងករណីមានការឆបោកពីក្រុមហ៊ុនដឹកជញ្ជូន។

## មាត្រា៣២ .- មរណភាពរបស់បុគ្គលទទួលខុសត្រូវ

ក្នុងករណីដែលបុគ្គលទទួលខុសត្រូវទទួលមរណភាព ការប្តឹងទាមទារសំណងពីអ្នកតំណាងដោយស្របច្បាប់របស់ក្រុមហ៊ុនដឹកជញ្ជូនអាចធ្វើបាន ដោយអនុលោមតាមបទប្បញ្ញត្តិនៃអនុសញ្ញានេះ។

## មាត្រា៣៣ .- យុត្តាធិការ

១- បណ្តឹងទាមទារសំណងខូចខាតត្រូវធ្វើឡើងតាមជម្រើសរបស់ដើមបណ្តឹងដែលអាចធ្វើឡើងនៅក្នុងដែនសមត្ថកិច្ចរបស់រដ្ឋភាគីណាមួយ ទាំងនៅតុលាការនៃទីតាំងនៃទីស្នាក់ការឬទីកន្លែងអាជីវកម្មចម្បងរបស់ក្រុមហ៊ុនដឹកជញ្ជូន ឬទីតាំងអាជីវកម្មរបស់ក្រុមហ៊ុនតាមរយៈនោះកិច្ចសន្យាត្រូវបានបង្កើតឡើង ឬទៅកាន់តុលាការ នៃទីកន្លែងគោលដៅ។

២- ពាក់ព័ន្ធនឹងការខូចខាតបណ្តាលមកពីមរណភាពឬការរងរបួសរបស់អ្នកដំណើរណាម្នាក់ ពាក្យបណ្តឹងអាចដាក់ទៅតុលាការណាមួយ ក្នុងចំណោមតុលាការ ដូចមានចែងក្នុងចំណុចទី១នៃមាត្រានេះ ឬនៅលើទឹកដីនៃរដ្ឋភាគីណាមួយដែលអ្នកដំណើរមានលំនៅឋានចម្បងនិងអចិន្ត្រៃយ៍តាំងនៅ នៅពេលដែលមានឧបទ្ទវហេតុកើតឡើង និងដែលក្រុមហ៊ុនដឹកជញ្ជូនមានប្រតិបត្តិការដឹកជញ្ជូនអ្នកដំណើរតាមផ្លូវអាកាសទៅឬមក ទាំងការប្រើប្រាស់អាកាសយានផ្ទាល់របស់ក្រុមហ៊ុនឬអាកាសយានរបស់ក្រុមហ៊ុនផ្សេងទៀត ផ្អែកលើកិច្ចព្រមព្រៀងពាណិជ្ជកម្ម មួយ និងដែលនៅក្នុងដែនដីនោះ ក្រុមហ៊ុនដឹកជញ្ជូនធ្វើប្រតិបត្តិការដឹកជញ្ជូនអ្នកដំណើរតាមផ្លូវអាកាសចេញពីទីតាំងដែលបានជួល ឬពីទីតាំងដែលជាកម្មសិទ្ធិផ្ទាល់របស់ក្រុមហ៊ុនដឹកជញ្ជូនខ្លួនឯង ឬរបស់ក្រុមហ៊ុនដឹកជញ្ជូន មួយផ្សេងទៀត ដែលមានកិច្ចព្រមព្រៀងពាណិជ្ជកម្មជាមួយគ្នា។

៣- តាមគោលបំណងនៃចំណុចទី២៖

(ក) "កិច្ចព្រមព្រៀងពាណិជ្ជកម្ម" សំដៅលើកិច្ចព្រមព្រៀងមួយ ក្រៅពីកិច្ចព្រមព្រៀងភ្នាក់ងារដែលធ្វើឡើងរវាងក្រុមហ៊ុនដឹកជញ្ជូននានាពាក់ព័ន្ធនឹងការផ្តល់សេវាកម្មដឹកជញ្ជូនអ្នកដំណើរតាមផ្លូវអាកាសរួមគ្នារបស់បុគ្គលទាំងនោះ។

(ខ) "លំនៅឋានចម្បងនិងអចិន្ត្រៃយ៍" សំដៅដល់ទីកន្លែងស្នាក់នៅតែមួយគត់ អចល័ត និងអចិន្ត្រៃយ៍របស់អ្នកធ្វើដំណើរ នៅពេលមានឧបទ្ទវហេតុកើតមានឡើង។ សញ្ជាតិរបស់អ្នកធ្វើដំណើរពុំមែនជាកត្តាកំណត់លើចំណុចនេះទេ។

៤- បញ្ហានីតិវិធីត្រូវគ្រប់គ្រងដោយច្បាប់របស់តុលាការដែលមានសមត្ថកិច្ចទទួលរឿងក្តី។

## មាត្រា៣៤ .- មជ្ឈត្តការ

១- យោងតាមបទប្បញ្ញត្តិនៃមាត្រានេះ គូភាគីនៃកិច្ចសន្យាដឹកជញ្ជូនទំនិញអាចចែងថា រាល់ជម្លោះពាក់ព័ន្ធនឹងការទទួលខុសត្រូវរបស់ក្រុមហ៊ុនដឹកជញ្ជូន យោងតាមអនុសញ្ញានេះ ត្រូវដោះស្រាយតាមរយៈមជ្ឈត្តកម្ម។ ការព្រមព្រៀងនេះត្រូវធ្វើជាលាយលក្ខណ៍អក្សរ។

២- ដំណើរការនីតិវិធីមជ្ឈត្តការ ត្រូវធ្វើឡើងតាមជម្រើសរបស់ភាគីប្ដឹងទាមទារដែលអាចធ្វើឡើងនៅក្នុងយុត្តាធិការណាមួយ ដូចមានចែងក្នុងមាត្រា៣៣។

៣- មជ្ឈត្តករ ឬវេទិកាមជ្ឈត្តកម្ម ត្រូវអនុវត្តបទប្បញ្ញត្តិនៃអនុសញ្ញានេះ។

៤- បទប្បញ្ញត្តិនៃចំណុចទី២និងចំណុចទី៣នៃមាត្រានេះ ត្រូវចាត់ទុកថា ជាផ្នែកមួយនៃគ្រប់ខចែងអំពីមជ្ឈត្តការ ឬកិច្ចព្រមព្រៀង ហើយខ្លឹមសារទាំងឡាយណាដែលផ្ទុយពីខចែងឬកិច្ចព្រមព្រៀងនេះ ត្រូវចាត់ទុកជាមោឃៈ។

## មាត្រា៣៥ .- ដែនកំណត់នៃសកម្មភាពបណ្ដឹង

១- សិទ្ធិទទួលបានសំណងពីការខូចខាតត្រូវរលត់ ប្រសិនបើបណ្ដឹងមិនត្រូវបានធ្វើឡើងក្នុងរង្វង់រយៈពេល២ (ពីរ)ឆ្នាំ គិតចាប់ពីថ្ងៃមកដល់ទីកន្លែងគោលដៅ ឬចាប់ពីថ្ងៃដែលអាកាសយានគួរតែបានមកដល់ ឬចាប់ពីថ្ងៃដែល ការដឹកជញ្ជូនបានបញ្ចប់។

២- វិធីសាស្ត្រក្នុងការគណនារយៈពេលនេះ ត្រូវកំណត់ដោយច្បាប់របស់តុលាការ ដែលមានសមត្ថកិច្ចទទួលពាក្យបណ្ដឹង។

## មាត្រា៣៦ .- ការដឹកជញ្ជូនបន្តបន្ទាប់គ្នា

១- ក្នុងករណីដែលការដឹកជញ្ជូន ត្រូវធ្វើឡើងដោយក្រុមហ៊ុនដឹកជញ្ជូនច្រើនបន្តបន្ទាប់គ្នា ស្របតាមនិយមន័យដូចមានចែងក្នុងចំណុចទី៣នៃមាត្រា១ ក្រុមហ៊ុនដឹកជញ្ជូននីមួយៗដែលទទួលយកអ្នកដំណើរ អីវ៉ាន់ឬទំនិញ ត្រូវស្ថិតក្រោមវិធាននានា ដូចមានចែងក្នុងអនុសញ្ញានេះ និងត្រូវចាត់ទុកជាភាគីមួយក្នុងចំណោមគូភាគីនៃកិច្ចសន្យាដឹកជញ្ជូន ក្នុងលក្ខខណ្ឌដែលកិច្ចសន្យានេះពាក់ព័ន្ធនឹងផ្នែកដឹកជញ្ជូនដែលប្រតិបត្តិឡើងក្រោមការត្រួតពិនិត្យរបស់ក្រុមហ៊ុនដឹកជញ្ជូននោះ។

២- ក្នុងករណីនៃការដឹកជញ្ជូនបែបនេះ អ្នកធ្វើដំណើរឬបុគ្គលមានសិទ្ធិទទួលសំណង អាចដាក់ពាក្យប្ដឹងក្រុមហ៊ុនដឹកជញ្ជូនដែលប្រតិបត្តិការដឹកជញ្ជូន ដែលក្នុងកំលុងពេលនោះមានឧបទ្ទវហេតុឬការយឺតយ៉ាវកើតឡើង លើកលែងតែក្នុងករណីដែលក្រុមហ៊ុនដឹកជញ្ជូនដំបូងគេ បានរ៉ាប់រងលើការទទួលខុសត្រូវសម្រាប់ការដឹកជញ្ជូនទាំងមូលដោយមានការព្រមព្រៀងជាក់លាក់។

៣- ចំពោះអីវ៉ាន់ឬទំនិញ អ្នកដំណើរឬអ្នកផ្ញើត្រូវមានសិទ្ធិប្ដឹងក្រុមហ៊ុនដឹកជញ្ជូនដំបូងគេ ឯអ្នកដំណើរឬអ្នកទទួលបញ្ញើត្រូវមានសិទ្ធិប្ដឹងក្រុមហ៊ុនដឹកជញ្ជូនចុងក្រោយគេ ដែលបានប្រតិបត្តិការដឹកជញ្ជូន ដែលក្នុងពេលនោះមានការបំផ្លាញ ការបាត់បង់ ការខូចខាត ឬការយឺតយ៉ាវបានកើតឡើង។ ក្រុមហ៊ុនដឹកជញ្ជូនទាំងនេះត្រូវទទួលខុសត្រូវរួមគ្នាចំពោះអ្នកដំណើរ ឬអ្នកផ្ញើ ឬអ្នកទទួល។

**មាត្រា៣៧ .- សិទ្ធិឧបាស្រ័យចំពោះតតិយជន**

ពុំមានអ្វីក្នុងអនុសញ្ញានេះ នឹងធ្វើឱ្យប៉ះពាល់ដល់សំណួរដែលថា បុគ្គលដែលត្រូវទទួលខុសត្រូវចំពោះការខូចខាតដោយអនុលោមតាមបទប្បញ្ញត្តិនៃអនុសញ្ញានេះ មានសិទ្ធិឧបាស្រ័យចំពោះបុគ្គលដទៃទេ។

**ជំពូកទី៤**

**ការដឹកជញ្ជូនដោយមធ្យោបាយរួមគ្នា**

**មាត្រា៣៨ .- ការដឹកជញ្ជូនដោយមធ្យោបាយរួមគ្នា**

១- ក្នុងករណីនៃការដឹកជញ្ជូនដោយមធ្យោបាយរួមគ្នា ដោយផ្នែកខ្លះតាមផ្លូវអាកាស និងផ្នែកខ្លះតាមមធ្យោបាយដឹកជញ្ជូនផ្សេងទៀត បទប្បញ្ញត្តិនៃអនុសញ្ញានេះត្រូវអនុវត្តចំពោះតែការដឹកជញ្ជូនតាមផ្លូវអាកាសតែប៉ុណ្ណោះ យោងតាមចំណុចទី៤នៃមាត្រា១៨ ប្រសិនបើការដឹកជញ្ជូនតាមផ្លូវអាកាសស្របតាមលក្ខខណ្ឌនៃមាត្រា១។

២- ក្នុងករណីដឹកជញ្ជូនដោយមធ្យោបាយរួមគ្នា ពុំមានអ្វីក្នុងអនុសញ្ញានេះហាមឃាត់គូភាគីមិនឱ្យបញ្ចូលលក្ខខណ្ឌពាក់ព័ន្ធនឹងមធ្យោបាយដឹកជញ្ជូនផ្សេងទៀត ទៅក្នុងឯកសារដឹកជញ្ជូនតាមផ្លូវអាកាសទេ ក្នុងលក្ខខណ្ឌដែលបទប្បញ្ញត្តិនៃអនុសញ្ញានេះត្រូវបានគោរព ពាក់ព័ន្ធនឹងការដឹកជញ្ជូនតាមផ្លូវអាកាស។

**ជំពូកទី៥**

**ការដឹកជញ្ជូនតាមផ្លូវអាកាសធ្វើឡើងដោយបុគ្គលមិនមែនជាក្រុមហ៊ុនដឹកជញ្ជូនជាប់កិច្ចសន្យា**

**មាត្រា៣៩ .- ក្រុមហ៊ុនដឹកជញ្ជូនជាប់កិច្ចសន្យា ក្រុមហ៊ុនដឹកជញ្ជូនជាក់ស្ដែង**

បទប្បញ្ញត្តិនៃជំពូកនេះត្រូវអនុវត្តនៅពេលដែលបុគ្គលម្នាក់ (តទៅហៅថា "ក្រុមហ៊ុនដឹកជញ្ជូនជាប់កិច្ចសន្យា") ចុះកិច្ចសន្យាដឹកជញ្ជូនមួយក្រោមអនុសញ្ញានេះ ជាមួយអ្នកដំណើរម្នាក់ឬអ្នកផ្ញើ ឬជាមួយបុគ្គលម្នាក់តំណាងអ្នកដំណើរឬអ្នកផ្ញើ ហើយបុគ្គលម្នាក់ផ្សេង (តទៅហៅថា "ក្រុមហ៊ុនដឹកជញ្ជូនជាក់ស្ដែង") ប្រតិបត្តិការដឹកជញ្ជូនទាំងមូលឬដោយផ្នែក អាស្រ័យតាមអំណាចផ្ដល់ឱ្យដោយក្រុមហ៊ុនដឹកជញ្ជូនជាប់កិច្ចសន្យា ប៉ុន្តែមិនមែន ជាក្រុមហ៊ុនដឹកជញ្ជូនបន្តបន្ទាប់ពាក់ព័ន្ធនឹងផ្នែកនេះ តាមអត្ថន័យនៃអនុសញ្ញានេះ។ អំណាចនេះត្រូវសន្មតថា បានការក្នុងករណីដែលមិនមានភស្តុតាងបញ្ជាក់ផ្ទុយ។

## មាត្រា៤០ .- ការទទួលខុសត្រូវរៀងខ្លួនរបស់ក្រុមហ៊ុនដឹកជញ្ជូនជាប់កិច្ចសន្យា និងក្រុមហ៊ុនដឹកជញ្ជូនជាក់ស្តែង

ប្រសិនបើក្រុមហ៊ុនដឹកជញ្ជូនជាក់ស្តែងមួយប្រតិបត្តិការដឹកជញ្ជូនទាំងមូលឬដោយផ្នែក ដែលគ្រប់គ្រងដោយអនុសញ្ញានេះ អនុលោមតាមកិច្ចសន្យា ដូចមានចែងក្នុងមាត្រា៣៩ ទាំងក្រុមហ៊ុនដឹកជញ្ជូនជាប់កិច្ចសន្យា និងក្រុមហ៊ុនដឹកជញ្ជូនជាក់ស្តែង ត្រូវតែស្ថិតក្រោមវិធាននៃអនុសញ្ញានេះ គឺក្រុមហ៊ុនដឹកជញ្ជូនជាប់កិច្ចសន្យាទទួលខុសត្រូវចំពោះការដឹកជញ្ជូនទាំងមូល ឯក្រុមហ៊ុនដឹកជញ្ជូនជាក់ស្តែងទទួលខុសត្រូវតែលើការដឹកជញ្ជូនដែលខ្លួនប្រតិបត្តិប៉ុណ្ណោះ លើកលែងមានការបញ្ជាក់ផ្ទុយនៅក្នុងជំពូកនេះ។

## មាត្រា៤១ .- ការទទួលខុសត្រូវទៅវិញទៅមក

១- ការប្រព្រឹត្តនិងការមិនបានបំពេញកាតព្វកិច្ចនានារបស់ក្រុមហ៊ុនដឹកជញ្ជូនជាក់ស្តែង និងបុគ្គលិកនិងភ្នាក់ងាររបស់ក្រុមហ៊ុននេះដែលបានបំពេញភារកិច្ចក្នុងក្របខ័ណ្ឌនៃការងាររបស់បុគ្គលទាំងនោះ ត្រូវតែចាត់ទុកថាជាការប្រព្រឹត្តនិងការមិនបានបំពេញកាតព្វកិច្ចរបស់ក្រុមហ៊ុន ដឹកជញ្ជូនជាប់កិច្ចសន្យាដែរ ពាក់ព័ន្ធនឹងការដឹកជញ្ជូនដែលធ្វើឡើងដោយក្រុមហ៊ុនដឹកជញ្ជូនជាក់ស្តែង។

២- ការប្រព្រឹត្តនិងការមិនបានបំពេញកាតព្វកិច្ចរបស់ក្រុមហ៊ុនដឹកជញ្ជូនជាប់កិច្ចសន្យា និងបុគ្គលិកនិងភ្នាក់ងាររបស់ក្រុមហ៊ុនដែលបំពេញភារកិច្ចក្នុងក្របខ័ណ្ឌការងាររបស់បុគ្គលទាំងនោះ ត្រូវចាត់ទុកថា ជាការប្រព្រឹត្តនិងការមិនបានបំពេញកាតព្វកិច្ចរបស់ក្រុមហ៊ុនដឹកជញ្ជូនជាក់ស្តែងដែរ ពាក់ព័ន្ធនឹងការដឹកជញ្ជូនដែលធ្វើឡើងដោយក្រុមហ៊ុនដឹកជញ្ជូនជាក់ស្តែង។ ទោះជាយ៉ាងណាក្តីការប្រព្រឹត្តឬការមិនបានបំពេញកាតព្វកិច្ចនេះ មិនត្រូវដាក់បន្ទុកដល់ក្រុមហ៊ុនដឹកជញ្ជូនជាក់ស្តែងឱ្យទទួលខុសត្រូវលើសពីចំនួនទឹកប្រាក់ ដូចមានចែងក្នុងមាត្រា២១ មាត្រា២២ មាត្រា២៣ និងមាត្រា២៤ឡើយ។ ការព្រមព្រៀងពិសេសណាមួយ ដែលក្នុងនោះក្រុមហ៊ុនដឹកជញ្ជូនជាប់កិច្ចសន្យារ៉ាប់រងកាតព្វកិច្ចនានាដែលមិនតម្រូវដោយអនុសញ្ញានេះ ឬការបដិសេធ សិទ្ធិឬមធ្យោបាយការពារខ្លួនដែលផ្តល់ឱ្យដោយអនុសញ្ញានេះ ឬការប្រកាសពិសេសអំពីប្រយោជន៍នៅពេលប្រគល់ នៅគោលដៅ ដូចមានចែងក្នុងមាត្រា២២ នឹងមិនប៉ះពាល់ដល់ក្រុមហ៊ុនដឹកជញ្ជូនជាក់ស្តែងទេ លើកលែងតែមាន ការព្រមព្រៀងដោយក្រុមហ៊ុនដឹកជញ្ជូនជាក់ស្តែង។

## មាត្រា៤២ .- អ្នកទទួលបណ្តឹងនិងសេចក្តីណែនាំ

រាល់ការប្តឹងតវ៉ាឬសេចក្តីណែនាំដែលត្រូវបញ្ជូនទៅឱ្យក្រុមហ៊ុនដឹកជញ្ជូនក្រោមអនុសញ្ញានេះ ត្រូវមានអានុភាពដូចគ្នា ទោះបីជាដាក់បញ្ជូនទៅឱ្យក្រុមហ៊ុនដឹកជញ្ជូនជាប់កិច្ចសន្យាឬទៅឱ្យក្រុមហ៊ុនដឹកជញ្ជូនជាក់ស្តែងក៏ដោយ។ ទោះជា យ៉ាងនេះក្តី សេចក្តីណែនាំ ដូចមានចែងក្នុងមាត្រា១២ មានអានុភាព លុះត្រាតែការប្តឹងតវ៉ាឬសេចក្តីណែនាំនោះត្រូវបានដាក់បញ្ជូនទៅឱ្យក្រុមហ៊ុនដឹកជញ្ជូនជាប់កិច្ចសន្យា។

### មាត្រា៤៣ .- បុគ្គលិកនិងភ្នាក់ងារ

ចំពោះការដឹកជញ្ជូនដែលធ្វើឡើងដោយក្រុមហ៊ុនដឹកជញ្ជូនជាក់ស្តែង រាល់បុគ្គលិកឬភ្នាក់ងាររបស់ក្រុមហ៊ុននោះ ឬរបស់ក្រុមហ៊ុនដឹកជញ្ជូនជាប់កិច្ចសន្យា ត្រូវមានសិទ្ធិប្រើប្រាស់លក្ខខណ្ឌនិងកម្រិតទទួលខុសត្រូវ ដែលត្រូវអនុវត្តក្រោមអនុសញ្ញានេះ ចំពោះក្រុមហ៊ុនដឹកជញ្ជូនដែលមានបុគ្គលិកឬភ្នាក់ងារនោះធ្វើការ ប្រសិនបើបុគ្គលទាំងនោះមានភស្តុតាងបង្ហាញថាបានបំពេញភារកិច្ចនៅក្នុងវង្វង់វិសាលភាពនៃការងាររបស់ខ្លួន លើកលែងតែក្នុងករណីមានភស្តុតាងបង្ហាញថា បុគ្គលទាំងនោះបានប្រព្រឹត្តអំពើក្នុងរបៀបមួយ ដែលរារាំងមិនឱ្យកម្រិតទទួលខុសត្រូវអាចអនុវត្តបានស្របតាមអនុសញ្ញានេះ។

### មាត្រា៤៤ .- ការបូកសរុបនៃការខូចខាត

ចំពោះការដឹកជញ្ជូនដែលធ្វើឡើងដោយក្រុមហ៊ុនដឹកជញ្ជូនជាក់ស្តែង ចំនួនទឹកប្រាក់សរុប ដែលអាចទទួលបានពីក្រុមហ៊ុនដឹកជញ្ជូនជាក់ស្តែងនោះនិងក្រុមហ៊ុនជាប់កិច្ចសន្យា និងពីបុគ្គលិកនិងភ្នាក់ងាររបស់ក្រុមហ៊ុនទាំងនោះ ដែលបំពេញភារកិច្ចនៅក្នុងវង្វង់វិសាលភាពនៃការងាររបស់ខ្លួន មិនត្រូវលើសពីចំនួនទឹកប្រាក់ខ្ពស់បំផុតដែលជាបន្ទុករបស់ក្រុមហ៊ុនដឹកជញ្ជូនជាប់កិច្ចសន្យាឬក្រុមហ៊ុនដឹកជញ្ជូនជាក់ស្តែង ដោយអនុលោមតាមអនុសញ្ញានេះ ក៏ប៉ុន្តែពុំមានបុគ្គលណាម្នាក់ដូចបានលើកឡើងខាងលើ ត្រូវទទួលខុសត្រូវលើចំនួនទឹកប្រាក់លើសពីកម្រិតអនុវត្តចំពោះបុគ្គលនេះទេ។

### មាត្រា៤៥ .- អ្នកទទួលបណ្តឹង

ចំពោះការដឹកជញ្ជូនដែលធ្វើឡើងដោយក្រុមហ៊ុនដឹកជញ្ជូនជាក់ស្តែង បណ្តឹងទាមទារសំណងអាចធ្វើចំពោះក្រុមហ៊ុនដឹកជញ្ជូននោះឬក្រុមហ៊ុនដឹកជញ្ជូនជាប់កិច្ចសន្យា ឬក្រុមហ៊ុនទាំងពីររួមគ្នាឬដោយឡែកពីគ្នា ទៅតាមជម្រើសរបស់ដើមបណ្តឹង។ ប្រសិនបណ្តឹងធ្វើឡើងចំពោះក្រុមហ៊ុនដឹកជញ្ជូនណាមួយក្នុងចំណោមក្រុមហ៊ុនដឹកជញ្ជូនទាំងនោះ ក្រុមហ៊ុនដឹកជញ្ជូនជាប់បណ្តឹងនោះមានសិទ្ធិតម្រូវឱ្យក្រុមហ៊ុនដឹកជញ្ជូនមួយទៀតចូលរួមក្នុងរឿងក្តី រីឯនីតិវិធីនិងអានុភាពនានាត្រូវគ្រប់គ្រងដោយច្បាប់របស់តុលាការដែលទទួលបណ្តឹង។

### មាត្រា៤៦ .- យុត្តាធិការបន្ថែម

បណ្តឹងទាមទារសំណងខូចខាត ដូចមានចែងក្នុងមាត្រា៤៥ ត្រូវតែធ្វើឡើងទៅតាមជម្រើសរបស់ដើមបណ្តឹង ដោយត្រូវធ្វើឡើងនៅលើដែនសមត្ថកិច្ចរបស់រដ្ឋភាគីណាមួយ ទាំងនៅតុលាការដែលទទួលពាក្យបណ្តឹងប្រឆាំងនឹងក្រុមហ៊ុនដឹកជញ្ជូនជាប់កិច្ចសន្យា ដូចមានចែងក្នុងមាត្រា៣៣ ឬនៅតុលាការដែលមានយុត្តាធិការនៅទីកន្លែងដែលក្រុមហ៊ុនដឹកជញ្ជូនជាក់ស្តែងតាំងនៅ ឬនៅទីកន្លែងដែលជាទីតាំងនៃទីស្នាក់ការ ឬទីកន្លែងអាជីវកម្មចម្បងរបស់ក្រុមហ៊ុន។

### មាត្រា៤៧ .- មោឃភាពនៃបទប្បញ្ញត្តិកិច្ចសន្យា

បទប្បញ្ញត្តិនៃកិច្ចសន្យាទាំងឡាយណាដែលមានចេតនាបន្ធូរបន្ថយបន្ទុកក្រុមហ៊ុនដឹកជញ្ជូនជាប់កិច្ចសន្យា ឬក្រុមហ៊ុនដឹកជញ្ជូនជាក់ស្តែងពីការទទួលខុសត្រូវក្រោមជំពូកនេះ ឬកំណត់កម្រិតនៃការទទួលខុសត្រូវឱ្យទាបជាង

កម្រិតដែលត្រូវអនុវត្តក្រោមជំពូកនេះ ត្រូវចាត់ទុកជាមោឃៈ។ មោឃភាពនៃបទប្បញ្ញត្តិណាមួយនោះ នឹងមិនមានអានុភាពមោឃភាពដល់កិច្ចសន្យាទាំងមូល ដែលនៅតែមានអានុភាពស្របតាមបទប្បញ្ញត្តិនៃជំពូកនេះ។

## មាត្រា៤៨ ._ ទំនាក់ទំនងទៅវិញទៅមករវាងក្រុមហ៊ុនដឹកជញ្ជូនជាប់កិច្ចសន្យា និងក្រុមហ៊ុនដឹកជញ្ជូនជាក់ស្តែង

លើកលែងតែមានចែងដូចក្នុងមាត្រា៤៥ ពុំមានបទប្បញ្ញត្តិណាមួយក្នុងជំពូកនេះប៉ះពាល់ដល់សិទ្ធិនិងកាតព្វកិច្ចរបស់ក្រុមហ៊ុនដឹកជញ្ជូនរវាងគ្នានឹងគ្នា រួមទាំងសិទ្ធិឧបាស្រ័យឬសិទ្ធិទទួលសំណងខូចខាត។

## ជំពូកទី៦
## បទប្បញ្ញត្តិផ្សេងៗ

## មាត្រា៤៩ ._ ការអនុវត្តតម្រូវដោយអនុសញ្ញា

រាល់លក្ខខណ្ឌដូចមានចែងក្នុងកិច្ចសន្យាដឹកជញ្ជូន និងរាល់ការព្រមព្រៀងពិសេសដែលចូលជាធរមានមុនការខូចខាតបានកើតមានឡើង ដែលតាមរយៈនោះ គូភាគីមានចេតនារំលោភបំពានវិធាននានាដែលមានចែងក្នុងអនុសញ្ញានេះ ទោះបីមានការសម្រេចពីច្បាប់ដែលត្រូវអនុវត្តឬដោយការកែប្រែវិធានយុត្តាធិការក៏ដោយ ត្រូវចាត់ទុកជាមោឃៈ។

## មាត្រា៥០ ._ ការធានារ៉ាប់រង

រដ្ឋភាគីត្រូវតម្រូវឱ្យក្រុមហ៊ុនដឹកជញ្ជូនរបស់ខ្លួនរក្សាទុកការធានារ៉ាប់រងឱ្យបានគ្រប់គ្រាន់សម្រាប់ការទទួលខុសត្រូវក្រោមអនុសញ្ញានេះ។ ក្រុមហ៊ុនដឹកជញ្ជូនមួយអាចត្រូវរដ្ឋភាគីដែលខ្លួនធ្វើប្រតិបត្តិការ តម្រូវឱ្យផ្តល់ភស្តុតាងបញ្ជាក់ថា ខ្លួនបានរក្សាទុកការធានារ៉ាប់រងគ្រប់គ្រាន់ដែលគ្របដណ្តប់លើការទទួលខុសត្រូវ ក្រោមអនុសញ្ញានេះ។

## មាត្រា៥១ ._ ការដឹកជញ្ជូនធ្វើឡើងក្នុងកាលៈទេសៈពិសេស

| ២៤៨- | លោក | ឃាង សុង | គ្រូបង្រៀនអនុវិទ្យាល័យ ប៊ុន រ៉ានី ហ៊ុនសែន ចំបក់ ស្រុកមេមត់ |
| ២៤៩- | លោក | ហ៊ាង គាន | គ្រូបង្រៀនអនុវិទ្យាល័យ ប៊ុន រ៉ានី ហ៊ុនសែន បុស្សតាអឹម ស្រុកមេមត់ |
| ២៥០- | លោកស្រី | ឈាន់ ស្រីធន់ | គ្រូបង្រៀនអនុវិទ្យាល័យ ប៊ុន រ៉ានី ហ៊ុនសែន មេមង ស្រុកមេមត់ |
| ២៥១- | លោកស្រី | ហុក គន្ធា | គ្រូបង្រៀនអនុវិទ្យាល័យ ប៊ុន រ៉ានី ហ៊ុនសែន កំពាន ស្រុកមេមត់ |
| ២៥២- | លោក | ហាយ សុខហួ | គ្រូបង្រៀនអនុវិទ្យាល័យ ប៊ុន រ៉ានី ហ៊ុនសែន ក្រវៀនធំ ស្រុកមេមត់ |
| ២៥៣- | លោក | ប៉ាង សុភ័ក្ត្រ | គ្រូបង្រៀនអនុវិទ្យាល័យតេជោសែនផ្លាកសំរោង ស្រុកមេមត់ |
| ២៥៤- | លោក | ផន សុខផេង | គ្រូបង្រៀនវិទ្យាល័យសម្តេចតេជោ ហ៊ុន សែន សួង ក្រុងសួង |
| ២៥៥- | លោកស្រី | ប៊ុន សេងហុង | គ្រូបង្រៀនវិទ្យាល័យសម្តេចតេជោ ហ៊ុន សែន សួង ក្រុងសួង |
| ២៥៦- | លោកស្រី | សូ ស៊ីណា | គ្រូបង្រៀនវិទ្យាល័យសម្តេចតេជោ ហ៊ុន សែន សួង ក្រុងសួង |
| ២៥៧- | លោកស្រី | ស្តើង ភារី | គ្រូបង្រៀនអនុវិទ្យាល័យរស្មីកុមារ ក្រុងសួង |
| ២៥៨- | លោក | ឯម សំអឿន | គ្រូបង្រៀនអនុវិទ្យាល័យទួលក្ដី ក្រុងសួង |
| ២៥៩- | លោក | ឈន ស្រ៊ត | គ្រូបង្រៀនសាលាបឋមសិក្សាភូមិ៤៨ ក្រុងសួង |
| ២៦០- | លោកស្រី | ហេង សុភី | គ្រូបង្រៀនសាលាបឋមសិក្សារស្មីសាមគ្គីឆ្លក ក្រុងសួង |
| ២៦១- | លោក | ចាន់ធី ទ្រី | គ្រូបង្រៀនសាលាបឋមសិក្សាពណ្ណរាយ ក្រុងសួង |
| ២៦២- | លោកស្រី | ប្រាក់ ណារិន | គ្រូបង្រៀនសាលាបឋមសិក្សាជ្រៃបិទមាស ក្រុងសួង |
| ២៦៣- | លោកស្រី | ធៀម ចន្ទធឿន | គ្រូបង្រៀនសាលាបឋមសិក្សាទួលក្ដី ក្រុងសួង |
| ២៦៤- | លោក | ហេង សារ៉ាត់ | គ្រូបង្រៀនវិទ្យាល័យ ហេង សំរិន ចក ស្រុកអូររាំងឪ |
| ២៦៥- | លោក | សុទ្ធ សុជាតិ | គ្រូបង្រៀនវិទ្យាល័យ ហេង សំរិន ចក ស្រុកអូររាំងឪ |
| ២៦៦- | លោក | ថន គង្គា | គ្រូបង្រៀនអនុវិទ្យាល័យ ហ៊ុន សែន ទួលសូភី ស្រុកអូររាំងឪ |
| ២៦៧- | លោកស្រី | ឡូត លក្ខិណា | គ្រូបង្រៀនអនុវិទ្យាល័យ ហ៊ុន សែន ទួលសូភី ស្រុកអូររាំងឪ |
| ២៦៨- | លោក | សន ដូង | គ្រូបង្រៀនអនុវិទ្យាល័យ ហ៊ុន សែន ទួលសូភី ស្រុកអូររាំងឪ |
| ២៦៩- | លោក | មន ភិដ្ឋរ៉ា | គ្រូបង្រៀនអនុវិទ្យាល័យ ហ៊ុន សែន ទួលសូភី ស្រុកអូររាំងឪ |

| | | | |
|---|---|---|---|
| ២៧០- | លោក | អៀង ស៊ីថានន្ត | គ្រូបង្រៀនអនុវិទ្យាល័យមៀន ស្រុកអូររាំងឪ |
| ២៧១- | លោកស្រី | ហ៊ាង នីតា | គ្រូបង្រៀនអនុវិទ្យាល័យមៀន ស្រុកអូររាំងឪ |
| ២៧២- | លោក | សុក ស៊ាប | គ្រូបង្រៀនសាលាបឋមសិក្សាថ្នល់កែងគងជ័យ ស្រុកអូររាំងឪ |
| ២៧៣- | លោកស្រី | ឡោ ណារីន | គ្រូបង្រៀនសាលាបឋមសិក្សាថ្នល់កែងព្រះធាតុ ស្រុកអូររាំងឪ |
| ២៧៤- | លោកស្រី | លី វួចឡេង | គ្រូបង្រៀនសាលាបឋមសិក្សាស្រែស្លែ ស្រុកអូររាំងឪ |
| ២៧៥- | លោកស្រី | យាន ឆៃវន | គ្រូបង្រៀនសាលាបឋមសិក្សាដំរិល ស្រុកអូររាំងឪ |

**មាត្រា២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃសុក្រ ១៤ រោច ខែស្រាពណ៍ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៨ ខែកក្កដា ឆ្នាំ២០២៤

**នាយករដ្ឋមន្ត្រី**

**សម្ដេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្ដេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ១៣៧ សសរ

## សេចក្តីសម្រេច
## ស្តីពី
## ការតែងតាំងសមាសភាពបន្ថែមក្នុងក្រុមការងារពិសេសរបស់នាយករដ្ឋមន្ត្រី លើកិច្ចការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តសកម្មភាព និងវិធានការអាទិភាពក្នុងវិស័យអប់រំ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ២៧៦ អនក្រ.បក ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការបង្កើតខុទ្ទកាល័យឯកឧត្តមកិត្តិទេសាភិបាលបណ្ឌិត **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល លេខ៨៧ សសរ ចុះថ្ងៃទី២ ខែឧសភា ឆ្នាំ២០២៤ ស្តីពីការបង្កើតក្រុមការងារពិសេសរបស់នាយករដ្ឋមន្ត្រីលើកិច្ចការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តសកម្មភាព និងវិធានការអាទិភាពក្នុងវិស័យអប់រំ
- យោងតាមតម្រូវការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**ប្រការ១ .-**

ត្រូវបានតែងតាំងសមាសភាពបន្ថែមក្នុងក្រុមការងារពិសេសរបស់នាយករដ្ឋមន្ត្រី លើកិច្ចការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តសកម្មភាព និងវិធានការអាទិភាពក្នុងវិស័យអប់រំ ចំណុះខុទ្ទកាល័យនាយករដ្ឋមន្ត្រី ដែលមានសមាសភាពដូចខាងក្រោម ៖

| | | |
|---|---|---|
| ១. ឯកឧត្តម | **គង់ វីរៈ** | សមាជិក |
| ២. ឯកឧត្តម | **អ៊ឹម សុខរិទ្ធី** | សមាជិក |

| | | |
|---|---|---|
| ៣. ឯកឧត្តម | **ឆិន ឆីណា** | សមាជិក |
| ៤. ឯកឧត្តម | **អ៊ុំ ដារិទ្ធ** | សមាជិក |
| ៥. ឯកឧត្តម | **ញឹម សុធាវិន្ទ** | សមាជិក |
| ៦. ឯកឧត្តម | **ចាំ សឿន** | សមាជិក |
| ៧ .ឯកឧត្តម | **ព្រាប ចាន់ម៉ារ៉ា** | សមាជិក |
| ៨. ឯកឧត្តម | **ហ៊ុន ឈុនតេង** | សមាជិក |
| ៩. ឯកឧត្តម | **ឡេង ស៊ីវ៉េង** | សមាជិក |
| ១០. ឯកឧត្តម | **ទស្ស សុមនាថ** | សមាជិក |
| ១១. ឯកឧត្តម | **សាម ច័ន្ទវីរៈ** | សមាជិក |
| ១២. ឯកឧត្តម | **សួង សុខរ៉ូ** | សមាជិក |
| ១៣. ឯកឧត្តម | **ភិន សំណាង** | សមាជិក។ |

**ប្រការ២ ..**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងប្រធានក្រុមការងារពិសេសរបស់នាយករដ្ឋមន្ត្រីលើកិច្ចការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តសកម្មភាព និងវិធានការអាទិភាពក្នុងវិស័យអប់រំ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃអង្គារ ១១ កើត ខែ អាសាឍ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ២០២៤

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

**កន្លែងទទួល**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ១៣៨ សសរ

# សេចក្តីសម្រេច
# ស្តីពី
# ការបង្កើតគណៈកម្មាធិការប្រតិបត្តិដឹកនាំការអនុវត្ត ផែនទីបង្ហាញផ្លូវការអភិវឌ្ឍវិស័យយានយន្ត និងអេឡិចត្រូនិកកម្ពុជា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- យោងតាមតម្រូវការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**ប្រការ១.-**

ត្រូវបានបង្កើត **គណៈកម្មាធិការប្រតិបត្តិដឹកនាំការអនុវត្តផែនទីបង្ហាញផ្លូវការអភិវឌ្ឍវិស័យយានយន្ត និងអេឡិចត្រូនិកកម្ពុជា** ដែលមានសមាសភាព ដូចខាងក្រោម៖

| | | | |
|---|---|---|---|
| ១- | ឯកឧត្តម **ស៊ុន ចាន់ថុល** | ឧបនាយករដ្ឋមន្ត្រី អនុប្រធានទី១ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | ប្រធាន |
| ២- | ឯកឧត្តម **ជា វុទ្ធី** | អគ្គលេខាធិការគណៈកម្មាធិការវិនិយោគកម្ពុជា នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | អនុប្រធាន |

| | | |
|---|---|---|
| ៣- ឯកឧត្តម **ផាន់ ផល្លា** | រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | អនុប្រធាន |
| ៤- លោកជំទាវ **សុវណ្ណា វណ្ណារតន៍** | រដ្ឋលេខាធិការប្រចាំការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | អនុប្រធាន |
| ៥- ឯកឧត្តម **រិត វុទ្ធី** | អគ្គលេខាធិការគណៈកម្មាធិការសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជា នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | សមាជិក |
| ៦- ឯកឧត្តម **ទី នរិន្ទ** | រដ្ឋលេខាធិការប្រចាំការក្រសួងរ៉ែ និងថាមពល | សមាជិក |
| ៧- ឯកឧត្តម **ហ៊ឹម យ៉ាន** | រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | សមាជិក |
| ៨- លោកជំទាវ **ខៀវ សុផានី** | រដ្ឋលេខាធិការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | សមាជិកា |
| ៩- ឯកឧត្តម **ប៊ុន ចន្ធី** | រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម | សមាជិក |
| ១០- ឯកឧត្តម **ទឹម ស៊ីនី** | រដ្ឋលេខាធិការក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | សមាជិក |
| ១១- ឯកឧត្តម **សាន វឌ្ឍនា** | រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា | សមាជិក |
| ១២- ឯកឧត្តម **ឡៅ ទិព្វសីហា** | រដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | សមាជិក |
| ១៣- ឯកឧត្តម **គង់ ផល្លះ** | រដ្ឋលេខាធិការក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ | សមាជិក |
| ១៤- ឯកឧត្តម **នុត អ៊ុនវ័ណរ៉ា** | អគ្គលេខាធិការរងគណៈកម្មាធិការវិនិយោគកម្ពុជា នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | សមាជិក |
| ១៥- ឯកឧត្តម **សឹម រេត** | អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ១៦- ឯកឧត្តម **មាស សុផល** | អនុរដ្ឋលេខាធិការក្រសួងបរិស្ថាន | សមាជិក |
| ១៧- ឯកឧត្តម **ទឹម សុផា** | អនុរដ្ឋលេខាធិការក្រសួងសាធារណការ និងដឹកជញ្ជូន | សមាជិក |
| ១៨- ឯកឧត្តម **ណុប សោភ័ណសារា** | អគ្គលេខាធិការរងអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | សមាជិក |

១៩- ឯកឧត្តម **ជា សុជាតិ** នាយករងខុទ្ទកាល័យ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី អនុប្រធានទី១ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា សមាជិក

គណៈកម្មាធិការប្រតិបត្តិដឹកនាំការអនុវត្តផែនទីបង្ហាញផ្លូវការអភិវឌ្ឍវិស័យយានយន្ត និងអេឡិចត្រូនិកកម្ពុជានេះ មានភារកិច្ច ដូចខាងក្រោម៖

- កំណត់ទិសដៅយុទ្ធសាស្ត្រនៃការអនុវត្តផែនទីបង្ហាញផ្លូវការអភិវឌ្ឍវិស័យយានយន្ត និងអេឡិចត្រូនិកកម្ពុជា
- តាមដានវឌ្ឍនភាពជាប្រចាំ និងផ្តល់ទស្សនវិស័យ ដើម្បីអនុវត្តវិធានការក្នុងផែនទីបង្ហាញផ្លូវការអភិវឌ្ឍវិស័យយានយន្ត និងអេឡិចត្រូនិកកម្ពុជា
- ដោះស្រាយបញ្ហាប្រឈមចម្បងៗដែលមានលក្ខណៈជាយុទ្ធសាស្ត្រ អន្តរវិស័យ និងមានអាទិភាពខ្ពស់ ដែលទាមទារការសម្រេចកម្រិតគោលនយោបាយ សម្រាប់ជំរុញការអភិវឌ្ឍវិស័យយានយន្ត និងអេឡិចត្រូនិក
- រាយការណ៍អំពីលទ្ធផលនៃ ការវាយតម្លៃការអនុវត្តផែនទីបង្ហាញផ្លូវការអភិវឌ្ឍវិស័យយានយន្ត និងអេឡិចត្រូនិកកម្ពុជា រៀងរាល់ ២ (ពីរ) ឆ្នាំម្តង ជូនគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (គ.ស.ហ.)។

**ប្រការ២.-**

គណៈកម្មាធិការប្រតិបត្តិដឹកនាំការអនុវត្តផែនទីបង្ហាញផ្លូវការអភិវឌ្ឍវិស័យយានយន្ត និងអេឡិចត្រូនិកកម្ពុជា មានរបបប្រជុំជាទៀងទាត់រៀងរាល់ ៦ (ប្រាំមួយ) ខែម្តង។

អនុប្រធាន និងសមាជិកគណៈកម្មាធិការ ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន។ ក្នុងករណី អនុប្រធាន ឬសមាជិកអវត្តមាន ត្រូវចាត់តាំងតំណាងដែលមានសិទ្ធិសម្រេច ចូលរួមប្រជុំជំនួស។

ក្នុងករណីអវត្តមាន ឬមានករណីចាំបាច់ ប្រធានអាចប្រគល់សិទ្ធិជូនអនុប្រធាន ដើម្បីដឹកនាំកិច្ចប្រជុំជំនួស។

ក្នុងករណីចាំបាច់ ប្រធានអាចកោះប្រជុំវិសាមញ្ញ។

គណៈកម្មាធិការប្រតិបត្តិដឹកនាំការអនុវត្តផែនទីបង្ហាញផ្លូវការអភិវឌ្ឍវិស័យយានយន្ត និងអេឡិចត្រូនិកកម្ពុជា មានគណៈកម្មាធិការដោះស្រាយបញ្ហាក្នុងវិស័យយានយន្តនិងអេឡិចត្រូនិក និងក្រុមការងារពន្លឿនវិស័យយានយន្តនិងអេឡិចត្រូនិក ជាសេនាធិការ។

**ប្រការ៣.-**

**គណៈកម្មាធិការដោះស្រាយបញ្ហាក្នុងវិស័យយានយន្តនិងអេឡិចត្រូនិក** ទទួលបន្ទុកជាសេនាធិការនៃគណៈកម្មាធិការប្រតិបត្តិដឹកនាំការអនុវត្តផែនទីបង្ហាញផ្លូវការអភិវឌ្ឍវិស័យយានយន្ត និង

អេឡិចត្រូនិកកម្ពុជា ដែលមានសមាសភាពដូចខាងក្រោម៖

| | | |
|---|---|---|
| ១- ឯកឧត្តម **ផាន់ ផល្លា** | រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ប្រធាន |
| ២- ឯកឧត្តម **សឹម រេត** | អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | អនុប្រធាន |
| ៣- ឯកឧត្តម **នុត អ៊ុនវ័ណារ៉ា** | អគ្គលេខាធិការរងគណៈកម្មាធិការវិនិយោគកម្ពុជា នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | អនុប្រធាន |
| ៤- ឯកឧត្តម **អ៊ូក សោភ័ណ** | អនុរដ្ឋលេខាធិការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | សមាជិក |
| ៥- ឯកឧត្តម **ឡាយ ណូរ៉ា** | អនុរដ្ឋលេខាធិការក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | សមាជិក |
| ៦- ឯកឧត្តម **ឆែ លីឌីន** | អនុរដ្ឋលេខាធិការក្រសួងរ៉ែ និងថាមពល | សមាជិក |
| ៧- ឯកឧត្តម **ជា សុជាតិ** | នាយករងខុទ្ទកាល័យ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី អនុប្រធានទី១ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | សមាជិក |
| ៨- ឯកឧត្តម **ហូ ស៊ីវយ៉ុង** | ប្រតិភូរាជរដ្ឋាភិបាលកម្ពុជាទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានសេវាពាណិជ្ជកម្ម នៃក្រសួងពាណិជ្ជកម្ម | សមាជិក |
| ៩- ឯកឧត្តម **ខ៉ែត ទិបុល** | អគ្គនាយកនៃអគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | សមាជិក |
| ១០- ឯកឧត្តម **លីម សុធា** | អគ្គនាយកនៃអគ្គនាយកដ្ឋានគោលនយោបាយ និងផែនការ នៃក្រសួងអប់រំ យុវជន និងកីឡា | សមាជិក |
| ១១- ឯកឧត្តម **សំ សិទ្ធិសេរី** | អគ្គនាយកនៃអគ្គនាយកដ្ឋានបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន នៃក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ | សមាជិក |
| ១២- ឯកឧត្តម **ឈួន វ៉ាន់** | អគ្គនាយកនៃអគ្គនាយកដ្ឋានដឹកជញ្ជូនផ្លូវគោក នៃក្រសួងសាធារណការ និងដឹកជញ្ជូន | សមាជិក |

| | | |
|---|---|---|
| ១៣- ឯកឧត្តម **ប្រុញ សុភាណា** | អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន ក្រុមប្រឹក្សាជាតិប្រាក់ឈ្នួលអប្បបរមា នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | សមាជិក |
| ១៤- ឯកឧត្តម ឧត្តមសេនីយ៍ឯក **ចេង ហាក់** | អគ្គស្នងការរងនៃអគ្គស្នងការដ្ឋាននគរបាលជាតិ នៃក្រសួងមហាផ្ទៃ | សមាជិក |
| ១៥- ឯកឧត្តម **ញាំ ស៊ីនិត** | នាយករងខុទ្ទកាល័យក្រសួងអប់រំ យុវជន និងកីឡា | សមាជិក |
| ១៦- លោក **យ៉ាន់ អ៊ាន់ជីលុច** | អគ្គនាយករងនៃអគ្គនាយកដ្ឋានសំណង់ នៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | សមាជិក |
| ១៧- លោក **អ៊ុក ណាវ៉ាន់** | អគ្គនាយករងនៃអគ្គនាយកដ្ឋាន គោលនយោបាយ និងយុទ្ធសាស្ត្រ នៃក្រសួងបរិស្ថាន | សមាជិក |
| ១៨- លោកឧត្តមសេនីយ៍ឯក **ម៉ុន ដា** | ប្រធាននាយកដ្ឋានកណ្តាលសណ្តាប់ធ្នាប់សាធារណៈនៃអគ្គស្នងការដ្ឋាននគរបាលជាតិ នៃក្រសួងមហាផ្ទៃ | សមាជិក |
| ១៩- លោក **អ៊ុន ចាន់ថា** | ប្រធាននាយកដ្ឋាននាំចេញនាំចូល នៃក្រសួងពាណិជ្ជកម្ម | សមាជិក |
| ២០- លោក **គិត នាគសែន** | ប្រធានការិយាល័យជួសជុលនិងថែទាំ នៃនាយកដ្ឋានសំណង់ នៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | សមាជិក |
| ២១- លោក **សោម រ៉ាឌុច** | ប្រធានការិយាល័យនៃអគ្គនាយកដ្ឋានបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន នៃក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ | សមាជិក |
| ២២- លោកស្រី **ជ្រា សៃសុគន្ធីដេត** | មន្ត្រីអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិប្រាក់ឈ្នួលអប្បបរមា នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | សមាជិកា |

គណៈកម្មាធិការដោះស្រាយបញ្ហាក្នុងវិស័យយានយន្តនិងអេឡិចត្រូនិកនេះ មានភារកិច្ចដូចខាងក្រោម៖

- ពិនិត្យ និងដោះស្រាយបញ្ហាប្រឈមសំខាន់ៗកម្រិតបច្ចេកទេស ក្នុងវិស័យយានយន្ត និងអេឡិចត្រូនិកដែលមានលក្ខណៈអន្តរវិស័យ
- បញ្ជូនទៅ គណៈកម្មាធិការប្រតិបត្តិដឹកនាំការអនុវត្តផែនទីបង្ហាញផ្លូវការអភិវឌ្ឍវិស័យយានយន្ត និងអេឡិចត្រូនិកកម្ពុជា នូវបញ្ហាជាក់លាក់ដែលពុំអាចដោះស្រាយបានដោយភ្ជាប់ជាមួយយោបល់បច្ចេកទេស
- សម្របសម្រួលផ្តល់ការគាំទ្រលើការអនុវត្តវិធានការជាក់លាក់ក្នុង ផែនទីបង្ហាញផ្លូវការអភិវឌ្ឍវិស័យយានយន្ត និងអេឡិចត្រូនិកកម្ពុជា។

**ប្រការ៤.-**

អនុប្រធាន សមាជិកគណៈកម្មាធិការដោះស្រាយបញ្ហាក្នុងវិស័យយានយន្តនិងអេឡិចត្រូនិក ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន។ ក្នុងករណី អនុប្រធាន ឬសមាជិកអវត្តមាន ត្រូវចាត់តាំងតំណាងដែលមានសិទ្ធិសម្រេច ចូលរួមប្រជុំជំនួស។

ក្នុងករណីអវត្តមាន ឬមានករណីចាំបាច់ ប្រធានអាចប្រគល់សិទ្ធិជូនអនុប្រធាន ដើម្បីដឹកនាំកិច្ចប្រជុំជំនួស។

**ប្រការ៥.-**

**ក្រុមការងារពន្លឿនវិស័យយានយន្តនិងអេឡិចត្រូនិក** ទទួលបន្ទុកជំរុញការអនុវត្តផែនទីបង្ហាញផ្លូវការអភិវឌ្ឍវិស័យយានយន្ត និងអេឡិចត្រូនិកកម្ពុជា ចំណុះឱ្យគណៈកម្មាធិការទាំងពីរខាងលើ ដែលមានសមាសភាពដូចខាងក្រោម៖

| | | | |
|---|---|---|---|
| ១- | ឯកឧត្តម **នុត អ៊ុនវ័ណារ៉ា** | អគ្គលេខាធិការរងគណៈកម្មាធិការវិនិយោគកម្ពុជា នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | ប្រធាន |
| ២- | ឯកឧត្តម **យ៉ុន ហេង** | អគ្គលេខាធិការរងគណៈកម្មាធិការវិនិយោគកម្ពុជា នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | អនុប្រធាន |
| ៣- | ឯកឧត្តម **ស៊ឹម រតេ** | អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | អនុប្រធាន |
| ៤- | ឯកឧត្តម **ហេង សុខណាង** | អគ្គលេខាធិការរងគណៈកម្មាធិការវិនិយោគកម្ពុជា នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | សមាជិក |
| ៥- | លោកជំទាវ **ទូច សុផារត្ន** | អនុរដ្ឋលេខាធិការក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ | សមាជិកា |

| | | | |
|---|---|---|---|
| ៦- | លោកជំទាវ **មូ ច័ន្ទគុលិកា** | អនុរដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា | សមាជិកា |
| ៧- | ឯកឧត្តម **សួន សុផល** | អគ្គលេខាធិការរងគណៈកម្មាធិការវិនិយោគកម្ពុជា នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | សមាជិក |
| ៨- | ឯកឧត្តម **សរ សិនិរ៉ា** | អគ្គលេខាធិការរងគណៈកម្មាធិការវិនិយោគកម្ពុជា នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | សមាជិក |
| ៩- | ឯកឧត្តម **ជា សុជាតិ** | នាយករងខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី អនុប្រធានទី១ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | សមាជិក |
| ១០- | ឯកឧត្តម **ឡោ ឆិត្យច័ន្ទសុភក្តិ** | ទីប្រឹក្សាអមក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | សមាជិក |
| ១១- | ឯកឧត្តម **ផា អេខម៉េខ** | អគ្គនាយករងនៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | សមាជិក |
| ១២- | លោក **តាន់ យុទរដ្ឋ** | អគ្គនាយករងនៃអគ្គនាយកដ្ឋានជំរុញពាណិជ្ជកម្ម នៃក្រសួងពាណិជ្ជកម្ម | សមាជិក |
| ១៣- | លោក **ចឹក ទិចិត្រ** | អគ្គនាយករងនៃវិទ្យាស្ថានស្តង់ដារកម្ពុជា នៃក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | សមាជិក |
| ១៤- | លោក **ស្រ៊ុន បញ្ញារិទ្ធ** | អគ្គនាយករងនៃអគ្គនាយកដ្ឋានវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ នៃក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | សមាជិក |
| ១៥- | លោក **រាត់ សិទ្ធ** | អគ្គនាយករងនៃអគ្គនាយកដ្ឋានគាំពារបរិស្ថាន នៃក្រសួងបរិស្ថាន | សមាជិក |
| ១៦- | លោក **ច័ន្ទធី សុជីវ៉ា** | អគ្គនាយករងនៃអគ្គនាយកដ្ឋានសាធារណការ នៃក្រសួងសាធារណការ និងដឹកជញ្ជូន | សមាជិក |

| | | | |
|---|---|---|---|
| ១៧- | លោក **សួន ខ៉ាន់ហុង** | អគ្គនាយករងនៃអគ្គនាយកដ្ឋានដឹកជញ្ជូនផ្លូវគោក នៃក្រសួងសាធារណការ និងដឹកជញ្ជូន | សមាជិក |
| ១៨- | លោក **ថង សាម៉ុន** | អគ្គនាយករងនៃអគ្គនាយកដ្ឋានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | សមាជិក |
| ១៩- | លោកឧត្តមសេនីយ៍ឯក**ហេង ចាន់ធារី** | ប្រធាននាយកដ្ឋាននគរបាលចរាចរណ៍និងសណ្តាប់ធ្នាប់សាធារណៈ នៃអគ្គស្នងការដ្ឋាននគរបាលជាតិ នៃក្រសួងមហាផ្ទៃ | សមាជិក |
| ២០- | លោក **អ៊ុច សាមិន** | ប្រធាននាយកដ្ឋានអភិវឌ្ឍន៍ទីផ្សារ នៃក្រសួងពាណិជ្ជកម្ម | សមាជិក |
| ២១- | លោក **សារិ ផល្លា** | ប្រធាននាយកដ្ឋានកិច្ចការឧស្សាហកម្ម នៃអគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | សមាជិក |
| ២២- | លោក **ឈួន សម្បត្តិរតនៈ** | ប្រធាននាយកដ្ឋានបច្ចេកទេស និងគោលនយោបាយអាជីវកម្មថាមពល នៃក្រសួងរ៉ែ និងថាមពល | សមាជិក |
| ២៣- | លោក **ជីវ ស៊ីវផេង** | ប្រធាននាយកដ្ឋានស្រាវជ្រាវបច្ចេកទេសសំណង់ នៃអគ្គនាយកដ្ឋានសំណង់ នៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | សមាជិក |
| ២៤- | លោក **សុផល ឡាស្កា** | ប្រធាននាយកដ្ឋានគ្រប់គ្រងសារធាតុគ្រោះថ្នាក់ នៃអគ្គនាយកដ្ឋានគាំពារបរិស្ថាន នៃក្រសួងបរិស្ថាន | សមាជិក |
| ២៥- | លោក **អៀង គំរ៉េង** | ប្រធាននាយកដ្ឋានឧស្សាហកម្មបច្ចេកវិទ្យា គមនាគមន៍ និងព័ត៌មាន នៃក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ | សមាជិក |

| | | | |
|---|---|---|---|
| ២៦- | លោក **ពេញ សុខារដ្ឋ** | ប្រធាននាយកដ្ឋាននិយ័តកម្មប្រេកង់សំរឹទ្ធ នៃក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ | សមាជិក |
| ២៧- | លោក **ខែម ពិសុទ្ធ** | ប្រធាននាយកដ្ឋានគោលនយោបាយ និងយុទ្ធសាស្ត្រ នៃក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ | សមាជិក |
| ២៨- | លោក **មុំ ពៅ** | ប្រធានផ្នែកប្រមូល និងផ្សព្វផ្សាយព័ត៌មាន នៃទីភ្នាក់ងារជាតិមុខរបរ និងការងារ នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | សមាជិក |
| ២៩- | លោក **ជា គៀត** | ប្រធានស្តីទីនាយកដ្ឋានទំនាក់ទំនងសាធារណៈនិងការជំរុញគម្រោងវិនិយោគឯកជន នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | សមាជិក |
| ៣០- | លោក **ហាម គីមឆេង** | ប្រធានស្តីទីនាយកដ្ឋានវិភាគគម្រោង និងការលើកទឹកចិត្ត | សមាជិក |
| ៣១- | លោក **ម៉ន សុចន្ថា** | ប្រធានស្តីទីនាយកដ្ឋាននីតិកម្ម និងច្បាប់វិនិយោគ នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | សមាជិក |
| ៣២- | លោក **ហៀន សុម៉ូលីន** | ប្រធានស្តីទីនាយកដ្ឋានប្រតិបត្តិការ និងគ្រប់គ្រងតំបន់សេដ្ឋកិច្ចពិសេស | សមាជិក |
| ៣៣- | លោក **សេង ស៊ុនលី** | ប្រធានស្តីទីនាយកដ្ឋានវិភាគយុទ្ធសាស្ត្រនៃការវិនិយោគឯកជន នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | សមាជិក |
| ៣៤- | លោកឧត្តមសេនីយ៍ត្រី **ថី វិសាល** | អនុប្រធាននាយកដ្ឋាននគរបាលចរាចរណ៍ និងសណ្តាប់ធ្នាប់សាធារណៈ នៃអគ្គស្នងការដ្ឋាននគរបាលជាតិ នៃក្រសួងមហាផ្ទៃ | សមាជិក |
| ៣៥- | លោក **កែវ វិចិត្រ** | អនុប្រធាននាយកដ្ឋានអភិវឌ្ឍថាមពល នៃក្រសួងរ៉ែ និងថាមពល | សមាជិក |

| | | | |
|---|---|---|---|
| ៣៦- | លោក **ភខ សុផាន់ណា** | អនុប្រធាននាយកដ្ឋានគោលនយោបាយ នៃក្រសួងអប់រំ យុវជន និងកីឡា | សមាជិក |
| ៣៧- | លោក **ឡុង វណ្ណា** | អនុប្រធាននាយកដ្ឋានស្រាវជ្រាវ បច្ចេកទេសសំណង់ នៃអគ្គនាយកដ្ឋាន សំណង់ នៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | សមាជិក |
| ៣៨- | លោក **ម៉ិល វ៉ានី** | អនុប្រធាននាយកដ្ឋានស្រាវជ្រាវ បច្ចេកទេសសំណង់ នៃអគ្គនាយកដ្ឋាន សំណង់នៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | សមាជិក |
| ៣៩- | លោក **លាង សុវិឡា** | អនុប្រធាននាយកដ្ឋានសេដ្ឋកិច្ចបៃតង នៃអគ្គនាយកដ្ឋានគោលនយោបាយ និងយុទ្ធសាស្ត្រនៃក្រសួងបរិស្ថាន | សមាជិក |
| ៤០- | លោកវរសេនីយ៍ទោ **ស៊ឹម វិសាល** | នាយរងការិយាល័យនគរបាលចរាចរណ៍ ផ្លូវគោក នៃនាយកដ្ឋាននគរបាល ចរាចរណ៍ និងសណ្តាប់ធ្នាប់សាធារណៈ នៃអគ្គស្នងការដ្ឋាននគរបាលជាតិ នៃក្រសួងមហាផ្ទៃ | សមាជិក |
| ៤១- | លោក **អេង ស៊ុនហួ** | មន្ត្រីនាយកដ្ឋាននិយ័តកម្មហ្វ្រេកង់ស៍ វិទ្យុនៃក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ | សមាជិក |

ក្រុមការងារពន្លឿនវិស័យយានយន្តនិងអេឡិចត្រូនិកនេះ មានភារកិច្ច ដូចខាងក្រោម៖

- ដឹកនាំ និងរៀបចំផែនការសកម្មភាពសម្រាប់ ការអនុវត្តវិធានការនីមួយៗក្នុងផែនទីបង្ហាញផ្លូវការអភិវឌ្ឍវិស័យយានយន្ត និងអេឡិចត្រូនិកកម្ពុជា
- តាមដាន និងរាយការណ៍ជាទៀងទាត់រៀងរាល់ ៦ (ប្រាំមួយ) ខែម្តង ជូនគណៈកម្មាធិការប្រតិបត្តិ ពីវឌ្ឍនភាពនៃការអនុវត្តវិធានការនីមួយៗ
- ប្រាស្រ័យទាក់ទងជាមួយវិនិយោគិនដើម្បីស្វែងយល់ពីទស្សនៈ និងបញ្ហាប្រឈម ក៏ដូចជានិន្នាការតំបន់និងសកលដែលអាចជះឥទ្ធិពលដល់វិស័យយានយន្ត និងអេឡិចត្រូនិក
- រាយការណ៍បញ្ហាប្រឈមក្នុងការអនុវត្តផែនទីបង្ហាញផ្លូវការអភិវឌ្ឍវិស័យយានយន្ត និងអេឡិចត្រូនិកកម្ពុជា និងដែលលើកឡើងដោយវិនិយោគិន ទៅគណៈកម្មាធិការ

ដោះស្រាយបញ្ហាក្នុងវិស័យយានយន្តនិងអេឡិចត្រូនិក ដើម្បីអន្តរាគមន៍ រកដំណោះ-ស្រាយទាន់ពេលវេលា។

**ប្រការ៦.-**

ក្រុមការងារពន្លឿនវិស័យយានយន្តនិងអេឡិចត្រូនិក មានរបបប្រជុំជាទៀងទាត់រៀងរាល់ ៣ (បី) ខែម្តង។

អនុប្រធាន សមាជិកក្រុមការងារ ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន។ ក្នុងករណីអនុប្រធាន ឬសមាជិកអវត្តមាន ត្រូវចាត់តាំងតំណាងដែលមានសិទ្ធិសម្រេចចូលរួមប្រជុំជំនួស។

ក្នុងករណីអវត្តមាន ឬមានករណីចាំបាច់ ប្រធានអាចប្រគល់សិទ្ធិជូនអនុប្រធាន ដើម្បីដឹកនាំកិច្ចប្រជុំជំនួស។

**ប្រការ៧.-**

គណៈកម្មាធិការប្រតិបត្តិដឹកនាំការអនុវត្តផែនទីបង្ហាញផ្លូវការអភិវឌ្ឍវិស័យយានយន្ត និងអេឡិចត្រូនិកកម្ពុជា គណៈកម្មាធិការដោះស្រាយបញ្ហាក្នុងវិស័យយានយន្តនិងអេឡិចត្រូនិក និងក្រុមការងារពន្លឿនវិស័យយានយន្តនិងអេឡិចត្រូនិក អាចអញ្ជើញតំណាងក្រសួង ស្ថាប័នពាក់ព័ន្ធដែលមិនមែនជាសមាជិកចូលរួមក្នុងកិច្ចប្រជុំ តាមការចាំបាច់។

**ប្រការ៨.-**

គណៈកម្មាធិការប្រតិបត្តិដឹកនាំការអនុវត្តផែនទីបង្ហាញផ្លូវការអភិវឌ្ឍវិស័យយានយន្ត និងអេឡិចត្រូនិកកម្ពុជា គណៈកម្មាធិការដោះស្រាយបញ្ហាក្នុងវិស័យយានយន្តនិងអេឡិចត្រូនិក និងក្រុម-ការងារពន្លឿនវិស័យយានយន្តនិងអេឡិចត្រូនិក មានលេខាធិការដ្ឋានដឹកនាំនិងសម្របសម្រួលការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ជាលេខាធិការដ្ឋាន។

លេខាធិការដ្ឋាន មានភារកិច្ចដូចខាងក្រោម៖

- ជាសេនាធិការរបស់ គណៈកម្មាធិការប្រតិបត្តិដឹកនាំការអនុវត្តផែនទីបង្ហាញផ្លូវការអភិវឌ្ឍវិស័យយានយន្ត និងអេឡិចត្រូនិកកម្ពុជា គណៈកម្មាធិការដោះស្រាយបញ្ហាក្នុងវិស័យយានយន្តនិងអេឡិចត្រូនិក និងក្រុមការងារពន្លឿនវិស័យយានយន្តនិងអេឡិចត្រូនិក លើការងារតាមដាន និងវាយតម្លៃការអនុវត្ត ផែនទីបង្ហាញផ្លូវការអភិវឌ្ឍវិស័យយានយន្ត និងអេឡិចត្រូនិកកម្ពុជា
- សម្របសម្រួលជាមួយក្រសួង ស្ថាប័ន វិស័យឯកជន ដៃគូអភិវឌ្ឍន៍ គ្រឹះស្ថានសិក្សាស្រាវជ្រាវ និងតួអង្គពាក់ព័ន្ធ ដើម្បីគាំទ្រការអនុវត្ត ផែនទីបង្ហាញផ្លូវការអភិវឌ្ឍវិស័យយានយន្ត និងអេឡិចត្រូនិកកម្ពុជា
- អនុវត្តភារកិច្ចផ្សេងៗទៀត តាមការប្រគល់ដោយគណៈកម្មាធិការប្រតិបត្តិដឹកនាំការអនុវត្តផែនទីបង្ហាញផ្លូវការអភិវឌ្ឍវិស័យយានយន្ត និងអេឡិចត្រូនិកកម្ពុជា គណៈកម្មា-

ធិការដោះស្រាយបញ្ហាក្នុងវិស័យយានយន្តនិងអេឡិចត្រូនិក និងក្រុមការងារពន្លឿនវិស័យយានយន្តនិងអេឡិចត្រូនិក។

**ប្រការ៩.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អនុប្រធានទី១ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា អនុប្រធានទី២ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ ព្រមទាំងសាមីខ្លួនដូចមានចែងក្នុងប្រការ១ ប្រការ៣ និងប្រការ៥ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃអង្គារ ១១ កើតខែអាសាឍ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែកក្កដា ឆ្នាំ២០២៤

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ ៩
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ :** ១៣៤៩...សសរ.....

# សេចក្តីសម្រេច
## ស្តីពី
## ការតែងតាំងសមាសភាពនៃអាជ្ញាធរជាតិទប់ស្កាត់អាវុធគីមី នុយក្លេអ៊ែរ ជីវសាស្ត្រ និងវិទ្យុសកម្ម

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការពារជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០៥/០០៥ ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអនុម័តយល់ព្រមលើអនុសញ្ញាស្តីពីអាវុធគីមី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៩/០២៣ ចុះថ្ងៃទី៣ ខែធ្នូ ឆ្នាំ២០០៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការហាមឃាត់អាវុធគីមី អាវុធនុយក្លេអ៊ែរ អាវុធជីវសាស្ត្រ និងអាវុធវិទ្យុសកម្ម
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦០៦/២៧៥ ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០០៦ ស្តីពីការបង្កើតអាជ្ញាធរជាតិទប់ស្កាត់អាវុធគីមី នុយក្លេអ៊ែរ ជីវសាស្ត្រ និងវិទ្យុសកម្ម
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤២៤/៤០២ ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលព្រះរាជក្រឹត្យស្តីពីការបង្កើតអាជ្ញាធរជាតិទប់ស្កាត់អាវុធគីមី នុយក្លេអ៊ែរ ជីវសាស្ត្រ និងវិទ្យុសកម្ម
- បានឃើញអនុក្រឹត្យលេខ២៨អនក្រ.បក ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០០៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាននៃអាជ្ញាធរជាតិទប់ស្កាត់អាវុធគីមី នុយក្លេអ៊ែរ ជីវសាស្ត្រ និងវិទ្យុសកម្ម
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការពារជាតិ

# សម្រេច

**ប្រការ១._**

ត្រូវបានតែងតាំងសមាសភាពនៃអាជ្ញាធរជាតិទប់ស្កាត់អាវុធគីមី នុយក្លេអ៊ែរ ជីវសាស្ត្រ និងវិទ្យុសកម្ម ដូចខាងក្រោម ៖

| | | | |
|---|---|---|---|
| ១. នាយឧត្តមសេនីយ៍ | **ទៀ សីហា** | ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ | ប្រធាន |
| ២. លោកជំទាវ | **ឆាយ វ៉ាន់ឡើន** | រដ្ឋលេខាធិការ ទីស្តីការគណៈរដ្ឋមន្ត្រី | អនុប្រធាន |
| ៣. នាយឧត្តមសេនីយ៍ | **ហ៊ីម យ៉ាន** | រដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ | អនុប្រធាន |
| ៤. ឯកឧត្តម | **កាន់ ផារិទ្ធ** | រដ្ឋលេខាធិការ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | អនុប្រធាន |
| ៥. ឯកឧត្តម | **កេង សុម៉ារិទ្ធ** | រដ្ឋលេខាធិការ ក្រសួងយុត្តិធម៌ | អនុប្រធាន |
| ៦. ឯកឧត្តម | **កែ គី** | រដ្ឋលេខាធិការ ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | អនុប្រធាន |
| ៧. ឯកឧត្តម | **អ៊ឹង អៀង** | រដ្ឋលេខាធិការ ក្រសួងរ៉ែ និងថាមពល | អនុប្រធាន |
| ៨. ឯកឧត្តម | **គុណា ញឹម** | រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជា អគ្គនាយក អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា | សមាជិក |
| ៩. ឯកឧត្តម | **ហ៊ីង សុវណ្ណ** | រដ្ឋលេខាធិការ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ១០. ឯកឧត្តម | **ហ៊ួត ប៊ុនណារី** | រដ្ឋលេខាធិការ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| ១១. ឯកឧត្តម | **ម៉េង សុធី** | រដ្ឋលេខាធិការ ក្រសួងពាណិជ្ជកម្ម | សមាជិក |
| ១២. ឯកឧត្តម | **សាបូ អូហ្សាណា** | រដ្ឋលេខាធិការ ក្រសួងបរិស្ថាន | សមាជិក |
| ១៣. ឯកឧត្តម | **សុត រស្មី** | រដ្ឋលេខាធិការ ក្រសួងធនធានទឹក និងឧតុនិយម | សមាជិក |
| ១៤. ឯកឧត្តម | **ខាយ យុនហេង** | រដ្ឋលេខាធិការ ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ | សមាជិក |
| ១៥. ឯកឧត្តម | **អ៊ឹង ភីរុន** | រដ្ឋលេខាធិការ ក្រសួងសុខាភិបាល | សមាជិក |
| ១៦. ឯកឧត្តម | **ជា ថោយ** | រដ្ឋលេខាធិការ ក្រសួងសាធារណការ និងដឹកជញ្ជូន | សមាជិក |
| ១៧. ឯកឧត្តម | **កែវ ស៊ីវន** | រដ្ឋលេខាធិការ រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល | សមាជិក |
| ១៨. នាយឧត្តមសេនីយ៍ | **ស ថេត** | អគ្គស្នងការ អគ្គស្នងការដ្ឋាននគរបាលជាតិ | សមាជិក |
| ១៩. នាយឧត្តមសេនីយ៍ | **ឥត សារ៉ាត់** | អគ្គមេបញ្ជាការរង និងជានាយសេនាធិការចម្រុះ នៃកងយោធពលខេមរភូមិន្ទ | សមាជិក |
| ២០. នាយឧត្តមសេនីយ៍ | **ផន ណារ៉ា** | អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិ ទប់ស្កាត់អាវុធគីមី នុយក្លេអ៊ែរ ជីវសាស្ត្រ និងវិទ្យុសកម្ម | សមាជិកអចិន្ត្រៃយ៍ |
| ២១. ឧត្តមសេនីយ៍ឯក | **ចៅ ភិរិទ្ធ** | អគ្គនាយក អគ្គនាយកដ្ឋានសម្ភារៈ បច្ចេកទេស ក្រសួងការពារជាតិ | សមាជិក |
| ២២. ឧត្តមសេនីយ៍ឯក | **ហុង វិណុល** | មេបញ្ជាការរង កងរាជអាវុធហត្ថលើផ្ទៃប្រទេស | សមាជិក។ |

**ប្រការ២._**

សេចក្តីសម្រេចលេខ០៨សសរ ចុះថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០២២ របស់រាជរដ្ឋាភិបាល ស្តីពីការតែងតាំងសមាសភាពនៃអាជ្ញាធរជាតិទប់ស្កាត់អាវុធគីមី នុយក្លេអ៊ែរ ជីវសាស្ត្រ និងវិទ្យុសកម្ម និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៣._**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃអង្គារ ១១ កើត ខែ អាសាឍ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ២០២៤

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ.៣៣.៥១....សហវ.ប្រក.ន.ក.ក

# ប្រកាស
## ស្តីពី
## ការបង្កើតក្រុមការងារអន្តរក្រសួងដើម្បីអនុវត្តការធានារ៉ាប់រងជាភាគព្វកិច្ច

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១២១/០០៣ ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០២១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨១៤/០២១ ចុះថ្ងៃទី៤ ខែសីហា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការធានារ៉ាប់រង
- បានឃើញអនុក្រឹត្យលេខ ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១១៣ អនក្រ.បក ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២១ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អង្គភាពក្រោមឱវាទរបស់អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA
mef.gov.kh
t.me/mefcambodia
ទូរស័ព្ទ: (+៨៥៥)២៣ ៨៩០ ៦៦៦
Phone: (+855) 23 890 666
info@mef.gov.kh
mef.cabinet@mef.gov.kh

- បានឃើញអនុក្រឹត្យលេខ ២៧៥ អនក្រ.បក ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២១ ស្ដីពីការធានារ៉ាប់រង
- បានឃើញប្រកាសអន្តរក្រសួងលេខ ៦៥៣ ប្រក.សហវ.សក.ទច.មផ ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០០២ ស្ដីពីកាតព្វកិច្ចធានារ៉ាប់រងភារៈទទួលខុសត្រូវយានយន្ត ឬធានារ៉ាប់រងតតិយជន
- បានឃើញប្រកាសអន្តរក្រសួងលេខ ៦៥៤ ប្រក.សហវ.សក.ទច.មផ ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០០២ ស្ដីពីកាតព្វកិច្ចធានារ៉ាប់រងការដឹកជញ្ជូនអ្នកដំណើរ
- បានឃើញប្រកាសអន្តរក្រសួងលេខ ៦៥៥ ប្រក.សហវ.ដនស.មផ ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០០២ ស្ដីពីកាតព្វកិច្ចធានារ៉ាប់រងភារៈទទួលខុសត្រូវការដ្ឋាន
- យោងតាមការស្នើរបស់និយ័តករធានារ៉ាប់រងកម្ពុជា

**សម្រេច**

**ប្រការ១.-**

ត្រូវបានបង្កើតក្រុមការងារអន្តរក្រសួងដើម្បីអនុវត្តការធានារ៉ាប់រងជាកាតព្វកិច្ច ដោយមានសមាសភាពដូចខាងក្រោម៖

| | | |
|---|---|---|
| ១. ឯកឧត្តម **រស់ សីលវ៉ា** | រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | ប្រធាន |
| ២. ឯកឧត្តម **ប៊ូ ច័ន្ទភីរូ** | អគ្គនាយកនៃនិយ័តករធានារ៉ាប់រងកម្ពុជា | អនុប្រធាន |
| ៣. ឯកឧត្តម **សុខ តុងហាប់** | រដ្ឋលេខាធិការក្រសួងទេសចរណ៍ | សមាជិក |
| ៤. ឯកឧត្តម **លី ចណ្ណាសូត្រ** | អនុរដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | សមាជិក |
| ៥. ឯកឧត្តម **សន សោភ័ណ** | អនុរដ្ឋលេខាធិការក្រសួងយុត្តិធម៌ | សមាជិក |
| ៦. លោក **ស្ទួន ម៉ាន់ហុង** | អគ្គនាយករងនៃអគ្គនាយកដ្ឋានដឹកជញ្ជូនផ្លូវគោក ក្រសួងសាធារណការ និងដឹកជញ្ជូន | សមាជិក |
| ៧. ឯកឧត្តម ឧត្តមសេនីយ៍ឯក **ចេង ហាក់** | អគ្គស្នងការរង នៃអគ្គស្នងការដ្ឋាននគរបាលជាតិ និងជាអនុប្រធានអចិន្ត្រៃយ៍អនុកម្មការត្រួតពិនិត្យការអនុវត្តច្បាប់ស្ដីពីចរាចរណ៍ផ្លូវគោកនៃគណៈកម្មាធិការជាតិសុវត្ថិភាពចរាចរណ៍ផ្លូវគោកក្រសួងមហាផ្ទៃ | សមាជិក |
| ៨. លោក **តឹក សុគឿន** | អគ្គនាយករងនៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុក្រសួងសុខាភិបាល | សមាជិក |
| ៩. លោកស្រីបណ្ឌិត **ហោ សុខឡូនា** | អគ្គនាយករងនៃនិយ័តករធានារ៉ាប់រងកម្ពុជា | សមាជិក |

| | | |
|---|---|---|
| ១០. លោក **ហ៊ុយ វ៉ាថារ៉ូ** | ប្រធានសមាគមធានារ៉ាប់រងកម្ពុជា | សមាជិក |
| ១១. លោកស្រី **ជិន សានីតា** | អនុប្រធានការិយាល័យសហប្រតិបត្តិការ នៃនិយ័តករធានារ៉ាប់រងកម្ពុជា | ជាលេខាធិការ។ |

**ប្រការ២ .-**

ក្រុមការងារអន្តរក្រសួងដើម្បីអនុវត្តការធានារ៉ាប់រងជាកាតព្វកិច្ច មានភារកិច្ចដូចខាងក្រោម៖

- ជំរុញការអនុវត្តការធានារ៉ាប់រងជាកាតព្វកិច្ច និងការដាក់ទណ្ឌកម្មផាកពិន័យចំពោះបទល្មើសទាំងឡាយដែលកំណត់ដោយច្បាប់និងលិខិតបទដ្ឋានគតិយុត្តិពាក់ព័ន្ធជាធរមាន
- ធ្វើអធិការកិច្ច និងការចុះត្រួតពិនិត្យដល់ទីកន្លែងលើការអនុវត្តកាតព្វកិច្ចរបស់ម្ចាស់យានយន្តគ្រប់ប្រភេទ ម្ចាស់ក្រុមហ៊ុនដឹកជញ្ជូនអ្នកដំណើរ និងម្ចាស់ការដ្ឋានសាងសង់ ក្នុងករណីចាំបាច់តាមលិខិតបញ្ជាបេសកកម្មរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ
- ចែករំលែក និងចងក្រងព័ត៌មាននិងទិន្នន័យអំពីការធានារ៉ាប់រងជាកាតព្វកិច្ច ទាំងផ្នែកទន់ និងផ្នែករឹង ជាប្រចាំ រវាងក្រសួងឬស្ថាប័នដែលជាសមាជិក ដោយផ្តល់របាយការណ៍ប្រចាំគ្រា តាមការកំណត់របស់ក្រុមការងារ
- ផ្សព្វផ្សាយ និងអប់រំសាធារណជន ម្ចាស់យានយន្តប្រកបអាជីវកម្ម ក្រុមហ៊ុនដឹកជញ្ជូនអ្នកដំណើរ និងម្ចាស់ការដ្ឋានទាំងអស់អំពីកាតព្វកិច្ចធានារ៉ាប់រងភារៈទទួលខុសត្រូវយានយន្ត កាតព្វកិច្ចធានា-រ៉ាប់រងការដឹកជញ្ជូនអ្នកដំណើរ កាតព្វកិច្ចធានារ៉ាប់រងភារៈទទួលខុសត្រូវការដ្ឋាន និងកាតព្វកិច្ចធានារ៉ាប់រងផ្សេងទៀត
- សិក្សា រៀបចំ និងធ្វើវិសោធនកម្មលិខិតបទដ្ឋានគតិយុត្តិពាក់ព័ន្ធការធានារ៉ាប់រងជាកាតព្វកិច្ច សិក្សានិងផ្តល់យោបល់អំពីតម្រូវការផលិតផលធានារ៉ាប់រងដែលត្រូវកំណត់ជាកាតព្វកិច្ចសម្រាប់អនុវត្តនៅក្នុងព្រះរាជាណាចក្រកម្ពុជា
- រាយការណ៍អំពីវឌ្ឍនភាពនៃការអនុវត្តការធានារ៉ាប់រងជាកាតព្វកិច្ចនិងសមិទ្ធផលការងាររបស់ក្រុមការងារជូនរាជរដ្ឋាភិបាលកម្ពុជា តាមរយៈរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ
- បំពេញភារកិច្ចផ្សេងៗទៀតតាមការប្រគល់ជូនរបស់ប្រធានក្រុមការងារ។

**ប្រការ៣ .-**

ក្រុមការងារអន្តរក្រសួងដើម្បីអនុវត្តការធានារ៉ាប់រងជាកាតព្វកិច្ចមាននាយកដ្ឋានស្រាវជ្រាវ បណ្តុះបណ្តាល និងសហប្រតិបត្តិការ នៃនិយ័តករធានារ៉ាប់រងកម្ពុជា នៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ ជាលេខាធិការដ្ឋាន ដែលមានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

- សម្របសម្រួល សិក្សា និងរៀបចំសេចក្តីព្រាងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធការធានារ៉ាប់រងជាកាតព្វកិច្ច
- សម្របសម្រួល និងតាមដានការងារផ្តល់របាយការណ៍របស់សមាជិកក្រុមការងារ
- សម្របសម្រួល និងរៀបចំកិច្ចប្រជុំ សិក្ខាសាលា ការអប់រំផ្សព្វផ្សាយ និងការចែករំលែកទិន្នន័យព័ត៌មាន
- សម្របសម្រួល និងរៀបចំបូកសរុបរបាយការណ៍ប្រចាំឆ្នាំរបស់ក្រុមការងារ
- បំពេញការងារផ្សេងទៀតតាមការណែនាំរបស់ប្រធានក្រុមការងារ។

**ប្រការ៤.-**

ក្រុមការងារអន្តរក្រសួងដើម្បីអនុវត្តការធានារ៉ាប់រងជាកាតព្វកិច្ចត្រូវមានរបបប្រជុំយ៉ាងយូរ ៦ (ប្រាំមួយ) ខែម្តង ក្នុង ១ (មួយ) ឆ្នាំ។ អនុប្រធាន និងសមាជិកក្រុមការងារ ត្រូវចូលរួមកិច្ចប្រជុំតាមការអញ្ជើញរបស់ប្រធានក្រុមការងារ។ ក្នុងករណីអវត្តមាន អនុប្រធាននិងសមាជិកក្រុមការងារត្រូវជូនដំណឹងនិងចាត់តំណាងចូលរួមប្រជុំជំនួស។

អនុប្រធានក្រុមការងារអាចដឹកនាំកិច្ចប្រជុំ តាមការប្រគល់សិទ្ធិរបស់ប្រធានក្រុមការងារ ។

ប្រធានក្រុមការងារ មានសិទ្ធិកោះអញ្ជើញភាគីពាក់ព័ន្ធផ្សេងទៀតចូលរួមកិច្ចប្រជុំតាមការចាំបាច់។

ក្រុមការងារអន្តរក្រសួងដើម្បីអនុវត្តការធានារ៉ាប់រងជាកាតព្វកិច្ចអាចបង្កើតអនុក្រុមការងារបច្ចេកទេសជាសេនាធិការតាមការចាំបាច់។

**ប្រការ៥.-**

ក្រុមការងារអន្តរក្រសួងដើម្បីអនុវត្តការធានារ៉ាប់រងជាកាតព្វកិច្ចអាចប្រើប្រាស់កញ្ចប់ថវិការបស់និយ័តករធានារ៉ាប់រងកម្ពុជាសម្រាប់រ៉ាប់រងចំណាយចាំបាច់ក្នុងការអនុវត្តតួនាទីរបស់ក្រុមការងារ។

ក្រុមការងារអន្តរក្រសួងដើម្បីអនុវត្តការធានារ៉ាប់រងជាកាតព្វកិច្ចអាចប្រើប្រាស់ត្រារបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**ប្រការ៦.-**

ប្រកាសលេខ ៤៥៨ សហវ.ប្រក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០២២ ស្តីពីការបង្កើតក្រុមការងារអន្តរក្រសួងដើម្បីអនុវត្តប្រកាសអន្តរក្រសួងស្តីពីកាតព្វកិច្ចធានារ៉ាប់រង ត្រូវទុកជានិរាករណ៍។

**ប្រការ៧ .-**

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្មនិងសំណង់ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន រដ្ឋមន្ត្រីក្រសួងទេសចរណ៍ អគ្គនាយកនៃនិយ័តករធានារ៉ាប់រងកម្ពុជានៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ និងសាមីខ្លួនដូចមានចែងក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

*ថ្ងៃអង្គារ ៤ រោច ខែជេស្ឋ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨*

*រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែមិថុនា គ.ស.២០២៤*

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

អគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ក្រសួងមហាផ្ទៃ
- ក្រសួងដែនដី នគរូបនីយកម្ម និងសំណង់
- ក្រសួងយុត្តិធម៌
- ក្រសួងសុខាភិបាល
- ក្រសួងសាធារណការនិងដឹកជញ្ជូន
- ក្រសួងទេសចរណ៍
- ខុទ្ទកាល័យសម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត
  នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- និយ័តករធានារ៉ាប់រងកម្ពុជា នៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ
- ដូចប្រការ១ និងប្រការ៧
  "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

MINISTRY OF ECONOMY AND FINANCE

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ.៣៣៣៣..សហវ.ក្រ.ឧភ.ឆាង

# ប្រកាសអន្តរក្រសួង

# ស្តីពី

# ការដាក់ឱ្យអនុវត្តអង្គភាពថវិកា

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**រដ្ឋមន្ត្រី**

**ក្រសួងរ៉ែ និងថាមពល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំង និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៧ ចុះថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរ៉ែ និងថាមពល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២៣/០០១ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៣៧ អនក្រ.បក ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរ៉ែ និងថាមពល
- បានឃើញអនុក្រឹត្យលេខ ៤២៦ អនក្រ.បក ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងដាក់ឱ្យអនុវត្តអង្គភាពថវិកា
- បានឃើញអនុក្រឹត្យលេខ ២៨៩ អនក្រ.បក ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៣ ស្តីពីការគ្រប់គ្រងថវិកា និងគណនេយ្យសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ២៤២ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០២១ ស្តីពីការបង្កើនចំនួនអង្គភាពថវិកា និងការប្រគល់សិទ្ធិជាអាណាប័កផ្ទេរសិទ្ធិជូនអង្គភាពថវិកា

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA
mef.gov.kh
t.me/mefcambodia
ទូរស័ព្ទ: (+៨៥៥)២៣ ៨៩០ ៦៦៦
Phone: (+855) 23 890 666
info@mef.gov.kh
mef.cabinet@mef.gov.kh

- បានឃើញប្រកាសលេខ ៥៤៤ សហវ.ប្រក ចុះថ្ងៃទី៩ ខែកញ្ញា ឆ្នាំ២០២១ ស្តីពីសិទ្ធិអំណាច ការទទួលខុសត្រូវ និងនីតិវិធីអនុវត្តថវិការបស់អង្គភាពថវិកា

## សម្រេច

**ប្រការ១.–**

ទទួលស្គាល់ និងដាក់ឱ្យអនុវត្តអង្គភាពថវិកាចំនួន ២៩ ដូចមានក្នុងឧបសម្ព័ន្ធភ្ជាប់នឹងប្រកាសអន្តរក្រសួងនេះ។

**ប្រការ២.–**

ប្រកាសអន្តរក្រសួងលេខ ៨៦២ រថ.អកទទ.ប្រក ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១៦ រវាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងរ៉ែ និងថាមពល ស្តីពីការដាក់ឱ្យអនុវត្តអង្គភាពថវិកា និងបទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសអន្តរក្រសួងនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៣.–**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ អគ្គនាយក អគ្គាធិការ ប្រធាននាយកដ្ឋាន ប្រធានមន្ទីររ៉ែ និងថាមពលរាជធានី ខេត្ត និងប្រធានអង្គភាពពាក់ព័ន្ធនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងរ៉ែ និងថាមពល ត្រូវទទួលបន្ទុកអនុវត្តប្រកាសអន្តរក្រសួងនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃសុក្រ ២រោច ខែពិសាខ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
រាជធានីភ្នំពេញ ថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០២៤

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន

រដ្ឋមន្ត្រី
ក្រសួងរ៉ែ និងថាមពល

កែវ_រតនៈ

កន្លែងទទួល÷

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ក្រសួង ស្ថាប័នពាក់ព័ន្ធ
- ដូចប្រការ៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ឧបសម្ព័ន្ធ ភ្ជាប់ប្រកាសអន្តរក្រសួងលេខ០៣៣ សហវ.ប្រក.អស. ចុះថ្ងៃទី២៦.....ខែឧសភា ឆ្នាំ២០២៤

ស្តីពីការដាក់ឱ្យអនុវត្តអង្គភាពថវិកា

| ល.រ. | ឈ្មោះអង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញ |
|---|---|
| I | អង្គភាពថវិកាថ្នាក់កណ្តាល |
| ១ | អគ្គនាយកដ្ឋានធនធានរ៉ែ |
| ២ | អគ្គនាយកដ្ឋានប្រេងកាត |
| ៣ | អគ្គនាយកដ្ឋានថាមពល |
| ៤ | អគ្គនាយកដ្ឋានកិច្ចការទូទៅ |
| II | អង្គភាពថវិកាថ្នាក់មូលដ្ឋាន |
| ១ | មន្ទីររ៉ែ និងថាមពលខេត្តបន្ទាយមានជ័យ |
| ២ | មន្ទីររ៉ែ និងថាមពលខេត្តបាត់ដំបង |
| ៣ | មន្ទីររ៉ែ និងថាមពលខេត្តកំពង់ចាម |
| ៤ | មន្ទីររ៉ែ និងថាមពលខេត្តកំពង់ឆ្នាំង |
| ៥ | មន្ទីររ៉ែ និងថាមពលខេត្តកំពង់ស្ពឺ |
| ៦ | មន្ទីររ៉ែ និងថាមពលខេត្តកំពង់ធំ |
| ៧ | មន្ទីររ៉ែ និងថាមពលខេត្តកំពត |
| ៨ | មន្ទីររ៉ែ និងថាមពលខេត្តកណ្តាល |
| ៩ | មន្ទីររ៉ែ និងថាមពលខេត្តកោះកុង |
| ១០ | មន្ទីររ៉ែ និងថាមពលខេត្តក្រចេះ |
| ១១ | មន្ទីររ៉ែ និងថាមពលខេត្តមណ្ឌលគិរី |
| ១២ | មន្ទីររ៉ែ និងថាមពលរាជធានីភ្នំពេញ |
| ១៣ | មន្ទីររ៉ែ និងថាមពលខេត្តព្រះវិហារ |
| ១៤ | មន្ទីររ៉ែ និងថាមពលខេត្តព្រៃវែង |
| ១៥ | មន្ទីររ៉ែ និងថាមពលខេត្តពោធិ៍សាត់ |
| ១៦ | មន្ទីររ៉ែ និងថាមពលខេត្តរតនគិរី |
| ១៧ | មន្ទីររ៉ែ និងថាមពលខេត្តសៀមរាប |
| ១៨ | មន្ទីររ៉ែ និងថាមពលខេត្តព្រះសីហនុ |
| ១៩ | មន្ទីររ៉ែ និងថាមពលខេត្តស្ទឹងត្រែង |

| | |
|---|---|
| ២០ | មន្ទីររ៉ែ និងថាមពលខេត្តស្វាយរៀង |
| ២១ | មន្ទីររ៉ែ និងថាមពលខេត្តតាកែវ |
| ២២ | មន្ទីររ៉ែ និងថាមពលខេត្តឧត្តរមានជ័យ |
| ២៣ | មន្ទីររ៉ែ និងថាមពលខេត្តកែប |
| ២៤ | មន្ទីររ៉ែ និងថាមពលខេត្តប៉ៃលិន |
| ២៥ | មន្ទីររ៉ែ និងថាមពលខេត្តត្បូងឃ្មុំ |

រក្សាសិទ្ធិនិងបោះពុម្ពដោយនាយកដ្ឋានរាជកិច្ច នៃ
អគ្គនាយកដ្ឋានរាជកិច្ចនិងតម្កល់ឯកសារជាតិ
ទីស្តីការគណៈរដ្ឋមន្ត្រី